## សៀវភៅណែនាំ ស្តីពី



# ការផ្សព្វផ្សាយព័ត៌មាន
# ជូនពលរដ្ឋអំពីលទ្ធកម្មសាធារណៈ
# នៅថ្នាក់ក្រោមជាតិ

បោះពុម្ពលើកទី១ ២០១៤

ការផ្សព្វផ្សាយព័ត៌មានជូនពលរដ្ឋអំពីលទ្ធកម្មសាធារណៈនៅថ្នាក់ក្រោមជាតិ

បោះពុម្ពលើកទី១ ដោយអង្គការសីលការ ឆ្នាំ២០១៤ ចំនួន ៥០០ក្បាល

**សៀវភៅណែនាំស្តីពី**

**ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្ម**

គាំទ្រថវិកាដោយ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់សហគ្រាសឯកជន (CIPE)

**រៀបរៀងដោយ៖**

អង្គការសីលការ និងសហការដោយភ្នាក់ងាររដ្ឋ (ខេត្តកំពង់ធំ)

រក្សាសិទ្ធិដោយអង្គការសីលការ ផ្ទះលេខ ៥៥B-៥៥C ផ្លូវលេខ ៣៩០សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ

លេខទំនាក់ទំនង០២៣ ២១៧ ៨៧២/ ០២៣ ២១០ ៩០២/ ០១២ ៧៩ ២៣ ៧៩

អ៊ីម៉ែល silaka@silaka.org / training@silaka.org

វែបសាយ www.silaka.org

អ្នកអាចចម្លងយកលំនាំតាម ចែកចាយ និងផ្ទេរផ្នែកណាមួយនៃមាតិកាសៀវភៅនេះ បានក្នុងគោលបំណង មិនរកប្រាក់ចំណេញ សូមអ្នកបញ្ជាក់ការរក្សាសិទ្ធិពីម្ចាស់ដើម។

# អារម្ភកថា

នេះជាសៀវភៅណែនាំ ស្តីពី "**ការផ្សព្វផ្សាយពត៌មានជាសាធារណៈអំពីលទ្ធកម្ម**" ចងក្រង ចេញពីការរៀនសូត្រ និងបទពិសោធន៍នៃគម្រោង "**ពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ**" នៅក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ប្រទេសកម្ពុជា។ គម្រោង អនុវត្តដោយអង្គការ សីលការ (SILAKA) និងមានកិច្ចសហការពីអង្គការអភិវឌ្ឍន៍ សេដ្ឋកិច្ច ជនបទ (MODE) ក្រោមកិច្ចគាំទ្រសហការពីមន្ត្រីសាធារណៈលទ្ធកម្ម ខេត្តកំពង់ធំ មន្ត្រីសាធារណៈ ក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ។

សៀវភៅនេះ រៀបចំចងក្រងឡើងដោយសាលាក្រុងស្ទឹងសែន និងសាលាស្រុកកំពង់ស្វាយ ក្នុងគោលបំណងចែករំលែកព័ត៌មានអំពីការបង្កើត "**ការផ្សព្វផ្សាយពត៌មានជាសាធារណៈ អំពីលទ្ធកម្ម**" ក្នុងកិច្ចលទ្ធកម្មសាធារណៈរបស់មន្ត្រីសាធារណៈក្រុងស្ទឹងសែន/ស្រុកកំពង់ស្វាយ។ វាជាព័ត៌មានដល់មន្ត្រីសាធារណៈ ថ្នាក់មូលដ្ឋានក្នុងស្រុកគោលដៅ បុគ្គលិកអង្គការមិនមែន រដ្ឋាភិបាល ប្រជាពលរដ្ឋកម្ពុជា ដែលមានគោលបំណងជម្រុញកិច្ចលទ្ធកម្ម សាធារណៈកាន់តែ មាន**តម្លាភាព** និង **គណនេយ្យភាព** ជាមួយយន្តការតវ៉ាតាមរយៈគណៈកម្មាធិការចម្រុះ ដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ។

ខ្លឹមសារនៃសៀវភៅ ចែកចេញជាបីផ្នែក។ ផ្នែកទី១៖ និយាយពីលទ្ធកម្ម និងការផ្សព្វផ្សាយ ព័ត៌មានជាសាធារណៈនៅក្នុងប្រទេសកម្ពុជា ផ្នែកទី២៖ និយាយពីការផ្សព្វផ្សាយព័ត៌អំពីកិច្ចលទ្ធ កម្មសាធារណៈ ផ្នែកទី៣៖ និយាយពី ការអនុវត្ត។

ខ្ញុំសង្ឃឹមថា សៀវភៅណែនាំនេះ នឹងជាជំនួយស្មារតីដល់សាធារណៈជន ក្នុងការចូលរួមកសាងសង្គមកម្ពុជា ឲ្យមានការរីកចំរើន តាមរយៈការពួតដៃគ្នា ធ្វើឲ្យកិច្ចលទ្ធសាធារណៈ ថ្នាក់មូលដ្ឋាន មានតម្លាភាព និងគណនេយ្យភាព ហើយឆ្លើយតបគោលនយោបាយអភិបាលកិច្ចល្អ របស់រាជរដ្ឋាភិបាល និងធ្វើឲ្យពលរដ្ឋទទួលបានប្រយោជន៍យ៉ាងពិតប្រាកដ។

សូមទទួលនូវគារវកិច្ចអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០១.....ខែ[illegible].........ឆ្នាំ២០១៤

**នាយិកាប្រតិបត្តិអង្គការសីលការ**

**ធីដា ឃិះ**

# សារពីសមាជិកក្រុមប្រឹក្សាខេត្តកំពង់ធំ

សៀវភៅណែនាំស្តីពី "**ការផ្សព្វផ្សាយពត៌មានជាសាធារណៈអំពីលទ្ធកម្ម**" របស់ក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលមិត្តអ្នកអានកំពុងកាន់ក្នុងដៃនេះ បានសម្រេចចេញជារូបរាង ពីការអនុវត្តគម្រោង "**ការពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ**" របស់អង្គការ សីលការ(SILAKA) និងអង្គការអភិវឌ្ឍ សេដ្ឋកិច្ចជនបទ(ម៉ូដ/MODE)។ សៀវភៅណែនាំនេះនឹងជាបច្ច័យដល់ សាធារណជន ក្នុងការចូលរួមកសាង និងអភិវឌ្ឍប្រទេសកម្ពុជា មានការរីកចម្រើន ស្របតាមយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ កន្លងមកយើងបានដឹងរួចទៅហើយថា ច្បាប់និងគោលការណ៍ណែនាំស្តីពីលទ្ធកម្ម សាធារណៈរបស់មូលនិធិឃុំ/សង្កាត់ មានភាពល្អប្រសើរ តែការអនុវត្តនៅមានកម្រិត ព្រោះអ្នកផ្តល់សេវាមួយចំនួនមិនទាន់គោរពបានតាមច្បាប់ដែលបានចែងនៅឡើយ។

ឆ្លៀតក្នុងឱកាសនេះ ក្នុងនាមនាងខ្ញុំជាសមាជិកក្រុមប្រឹក្សាខេត្ត ខ្ញុំសូមអបអរសាទរចំពោះស្នាដៃរបស់សាលាក្រុងស្ទឹងសែន និងសាលាស្រុកកំពង់ស្វាយ ក្នុងការបង្កើតឲ្យមាន គណៈកម្មាធិការដោះស្រាយទំនាស់របស់ពលរដ្ឋ ហើយថែមទាំងបានជួយគាំទ្រឲ្យមានការរៀបចំសៀវភៅស្តី**ការផ្សព្វផ្សាយពត៌មានជាសាធារណៈអំពីលទ្ធកម្ម** ដើម្បីរួមចំណែកក្នុងការពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិនៅខេត្តកំពង់ធំរបស់យើង។

ជាចុងបញ្ចប់ ខ្ញុំសូមជូនពរដល់អង្គការសីលការ អង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ មន្ត្រីពាក់ព័ន្ធនៃគណៈកម្មាធិការចម្រុះដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការនៃក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ ឲ្យមានជោគជ័យក្នុងការបំពេញភារកិច្ច និងឲ្យប្រព័ន្ធដោះស្រាយទំនាស់ជាសាធារណៈ ព្រមទាំងការផ្សព្វផ្សាយពត៌មានជាសាធារណៈអំពីលទ្ធកម្ម មានដំណើរការទៅមុខដោយរលូនសមស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។

ខេត្តកំពង់ធំ ថ្ងៃទី..២៩..ខែ...កញ្ញា.....ឆ្នាំ២០១៤

**សមាជិកក្រុមប្រឹក្សាខេត្តកំពង់ធំ**

**យស ថាវរី**

## សារពីនាយករង ទីចាត់ការផែនការនិងវិនិយោគនៃសាលាខេត្តកំពង់ធំ

យោងតាមប្រកាសលេខ ២៣១ សហវ ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥ និង អនុក្រឹត្យ ឆ្នាំ២០០៦ ស្តីពីការធ្វើកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ បានតម្រូវឲ្យរដ្ឋបាល ថ្នាក់ឃុំ សង្កាត់ មានកញ្ចប់ថវិកាមួយចំណែកដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធក្នុងមូលដ្ឋាន។ រដ្ឋបាលថ្នាក់ឃុំ សង្កាត់មានកម្មវិធីវិនិយោគ ហើយមានរៀបចំគម្រោង និងដាក់ឲ្យដេញថ្លៃជាសាធារណៈ តែកន្លងមក ពេលដេញថ្លៃមានក្រុមមួយចំនួនមិនបានគោរពតាមច្បាប់ លទ្ធកម្មសាធារណៈឡើយ។ ជាងនេះទៀត រាល់ពេលមានការដេញថ្លៃម្តងៗ កម្រនឹងមានការចូលរួមពីពលរដ្ឋ ទោះបីជាមានអញ្ជើញឲ្យចូលរួមពីអាជ្ញាធរក៏ដោយ។ ម្យ៉ាងទៀត ពេលមានការមិន ពេញចិត្តចំពោះការផ្តល់សេវា ពលរដ្ឋក៏មិនដឹងរកអន្តរាគមន៍ដោយវិធីណា។

ខ្ញុំពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលសាលាក្រុងស្ទឹងសែន និង សាលាស្រុកកំពង់ស្វាយ បានរៀបចំឲ្យមានគណៈកម្មាធិការដោះស្រាយទំនាស់ពលរដ្ឋ **អំពីកិច្ច-លទ្ធកម្ម** និងបានចងក្រងសៀវភៅណែនាំស្តី ប្រព័ន្ធដោះស្រាយការតវ៉ាជាសាធារណៈ ព្រមទាំង សៀវភៅណែនាំ ស្តីពី **ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្ម** នេះឡើង។ សៀវភៅទាំងនេះ នឹងបានជួយដល់ប្រជាពលរដ្ឋ និងមន្ត្រីពាក់ព័ន្ធទាំងឡាយក្នុងការទទួលបាន ព័ត៌មាន ស្តីពីការធ្វើលទ្ធកម្មក្នុងប្រទេសក៏ដូចជាការធ្វើលទ្ធកម្មក្នុង ឃុំ ស្រុក របស់ពួកគេ ដើម្បី ធ្វើឲ្យកិច្ចលទ្ធកម្មថ្នាក់ឃុំ សង្កាត់ កាន់តែមានតម្លាភាព និងគណនេយ្យភាព។

ជាចុងបញ្ចប់ ខ្ញុំសូមជូនពរឲ្យ**ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្ម** ទទួលបានជោគជ័យ និងសូមបានជាប្រយោជន៍ដល់សាធារណៈជនទូទៅ។

ខេត្តកំពង់ធំ ថ្ងៃទី២៩ខែកញ្ញា....ឆ្នាំ២០១៤

**នាយករងទីចាត់ការផែនការ និងវិនិយោគ**

**សស ប៉ាឡូ**

# សារពីអភិបាលនៃក្រុងស្ទឹងសែន

សៀវភៅណែនាំ ស្តីពី "**ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្ម**" ជាគម្រោងស្នាដៃថ្មីមួយរបស់សាលាក្រុងស្ទឹងសែន។ សៀវភៅណែនាំអំពីការផ្សព្វផ្សាយព័ត៌មាន ជាសាធារណៈអំពីលទ្ធកម្ម បានណែនាំនូវសេចក្តីសំខាន់ៗមួយចំនួន ដែលប្រជាពលរដ្ឋ អាជ្ញាធរ មន្ត្រីគម្រោង និងសាធារណៈជនទូទៅអាចស្វែងយល់ពីការទទួលបាន ព័ត៌មានទាក់ទងនឹងការធ្វើលទ្ធកម្មក្នុងប្រទេសកម្ពុជា។

ជាងនេះទៀត ពលរដ្ឋ អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនអ្នកផ្តល់សេវា ផ្នែកលទ្ធកម្មសាធារណៈ នឹងមានការយល់ដឹងពីរបៀបនៃការទទួលបានព័ត៌មានស្តីពីលទ្ធកម្ម យល់ដឹងពីតួនាទី និងសិទ្ធិ ព្រមទាំងអាចចូលរួមសង្កេតក្នុងការដេញថ្លៃ ដើម្បីឲ្យកិច្ចលទ្ធកម្មសាធារណៈកាន់តែមានតម្លាភាព និងគណនេយ្យភាព។ ដំណើរការនេះ នឹងញ៉ាំងឲ្យសេដ្ឋកិច្ចនៃប្រទេសកម្ពុជាមានការអភិវឌ្ឍយ៉ាងពិតប្រាកដ បើយើងចូលរួមធ្វើឲ្យកិច្ចលទ្ធកម្មសាធារណៈបានល្អប្រសើរ។

ម្យ៉ាងទៀត ទោះបីជាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្មជាយន្តការថ្មីរបស់សាលាក្រុងស្ទឹងសែនក៏ដោយ ក៏សាលាក្រុងនឹងខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ ចិត្ត ក្នុងការផ្សព្វផ្សាយព័ត៌មានស្តីពីការដេញថ្លៃ ដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងសហគមន៍ និងភូមិ សង្កាត់របស់ខ្លួន ឲ្យមានការយល់ដឹងពីការងារដេញថ្លៃ ដែលជាការងារអភិវឌ្ឍន៍ ក្នុងសហគមន៍របស់ពួកគេ។

ជាចុងបញ្ចប់ ខ្ញុំសូមឲ្យសាធារណៈជន មេត្តាស្វែងយល់ពីព័ត៌មាននៃការដេញថ្លៃជាសាធារណៈ របស់សាលាក្រុង និងសូមស្វាគមន៍ ចំពោះមតិយោបល់កែលម្អ ដើម្បីឲ្យសៀវភៅដែលនឹងបោះពុម្ពលើកក្រោយកាន់តែល្អប្រសើរ។

ស្ទឹងសែន, ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ២០១៥

**អភិបាលក្រុងស្ទឹងសែន**

**អភិបាល**

**ខែម ផា**

# សារពីអភិបាលនៃស្រុកកំពង់ស្វាយ

សៀវភៅណែនាំ ស្តីពី "**ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្ម**" ដែលលោក លោកស្រីកំពុងកាន់អានក្នុងដៃនេះ ជាកម្រងស្នាដៃថ្មីមួយរបស់សាលាស្រុកកំពង់ស្វាយ។ សៀវភៅនេះ នឹងបង្ហាញពីរបៀបនៃការ ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្ម ព្រមទាំងការចូលរួមវិភាគទានក្នុងការបង្កើតឲ្យមានភាពងាយស្រួលក្នុងការងារដេញថ្លៃ ក្នុងប្រទេសកម្ពុជា។

តាមរយៈសៀវភៅនេះ ខ្ញុំសង្ឃឹមថា ពលរដ្ឋនៃស្រុកកំពង់ស្វាយ មន្ត្រីអង្គការក្រៅរដ្ឋាភិបាល ក៏ដូចជាក្រុមហ៊ុនអ្នកផ្តល់សេវាផ្នែកលទ្ធកម្មសាធារណៈ នឹងយល់ច្បាស់ពី**ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្ម** ព្រមទាំងចូលរួមប្រើប្រាស់ប្រព័ន្ធនេះ ដើម្បីឲ្យកិច្ចលទ្ធកម្មសាធារណៈនៃស្រុកកំពង់ស្វាយយើង មានតម្លាភាព និងមានគណនេយ្យភាព ហើយអាចបំរើប្រយោជន៍ដល់ប្រជាពលរដ្ឋ យ៉ាងពិតប្រាកដ។

ជាចុងក្រោយ ខ្ញុំសូមឲ្យសាធារណជនចូលរួមក្នុងការធ្វើឲ្យកិច្ចលទ្ធកម្មសាធារណៈរបស់ស្រុកកំពង់ស្វាយមានដំណើរល្អ ដោយផ្អែកលើច្បាប់លទ្ធកម្មនៃព្រះរាជាណាចក្រកម្ពុជា។ ការចូលរួមរបស់លោក លោកស្រី នឹងជាវិភាគទាន ក្នុងចលនាកសាង និងអភិវឌ្ឍសង្គមកម្ពុជាឲ្យមានការរីកចំរើនជាក់ជាមិនខាន។

ខ្ញុំសង្ឃឹម និងជឿជាក់ថាការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្ម នឹងការខិតប្រឹងប្រែងអស់ពីសមត្ថភាពរបស់អាជ្ញាធរ ដោយឈរលើស្មារតីយុត្តិធម៌ នឹងបានជាប្រយោជន៍ដល់សាធារណៈជនក្នុងប្រទេសកម្ពុជា។

ថ្ងៃ..........ទី ២៩ ខែ កញ្ញា ឆ្នាំ២០១៤

**អភិបាលនៃស្រុកកំពង់ស្វាយ**

**ម៉ុត ឧណ្ណារ៉ា**

# សេចក្តីថ្លែងអំណរគុណ

ក្នុងដំណើរការរៀបចំ សៀវភៅណែនាំស្តីពី "**ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្ម**" បានចងក្រងឡើងដោយមានការគាំទ្រ ពីបុគ្គល/ស្ថាបនិកជាច្រើន។

យើងសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ចំពោះមន្ត្រីរដ្ឋាភិបាលនៃខេត្តកំពង់ធំ ដែលបានចូលរួមក្នុងការផ្តួចផ្តើមគំនិត កែសម្រួលខ្លឹមសារ ពាក្យពេចន៍នៃសៀវភៅនេះ និងចូលរួមឲ្យមាន ការបង្កើតសៀវភៅណែនាំស្តីពី **ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈអំពីលទ្ធកម្ម** ដែលក្នុងនោះយើងខ្ញុំសូមអរគុណដល់ ៖

១. លោកជំទាវ យស ថានារី សមាជិកក្រុមប្រឹក្សាខេត្តកំពង់ធំ

២. លោក ស ប៉ាហ្វ នាយករងនៃទីចាត់ការផែនការ និងវិនិយោគខេត្តកំពង់ធំ

៣. លោក ខែក ផា អភិបាលរងក្រុងស្ទឹងសែន ខេត្តកំពង់ធំ និងសហការី

៤.លោក អ៊ុត វណ្ណា៉ អភិបាលរងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងសហការី

ជាមួយគ្នាផងដែរ យើងខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងមហាផ្ទៃ ដែលបានអនុញ្ញាតិ ឲ្យគម្រោង "**ពង្រឹងអភិបាលកិច្ចលទ្ធកម្មសាធារណៈ**" បានអនុវត្តនៅក្រុងស្ទឹងសែន និង ស្រុក កំពង់ស្វាយ ដែលជាគម្រោងសាកល្បងលើកទី១ នៅខេត្តកំពង់ធំ ប្រទេសកម្ពុជា។

សូមថ្លែងអំណរគុណចំពោះ អង្គការសីលការ (SILAKA) និងអង្គការអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ (ម៉ូដ/MODE) ដែលបានអនុវត្តគម្រោងក្នុងក្រុងស្ទឹងសែន និងស្រុកកំពង់ស្វាយ និងតែងតែ ផ្តល់ជំនួយផ្នែកបច្ចេកទេសក្នុងការតាក់តែងឲ្យសៀវភៅនេះចេញជារូបរាងឡើង ជាពិសេស លោកស្រី ធីដា ឃិះ នាយិកាប្រតិបត្តិនៃ អង្គកាលសីលការ ដែលបានផ្តល់គំនិត និងមតិកែសម្រួលលើខ្លឹមសារសៀវភៅ និងត្រួតពិនិត្យលើអក្ខរាវិរុទ្ធ។

សូមថ្លែងអំណរគុណផងដែរដល់ មជ្ឈមណ្ឌលអន្តរជាតិ សម្រាប់សហគ្រាសឯកជន (CIPE) ដែលបានផ្តល់មូលនិធិសម្រាប់អនុវត្តគម្រោង និងការបោះពុម្ពផ្សាយនូវសៀវភៅនេះ សម្រាប់ចែក ចាយដល់ សាធារណជនទុកជាព័ត៌មាន និងជាចំណេះដឹងផងដែរ។

ថ្ងៃទី២៩ខែតុលា....ឆ្នាំ២០១៤

**ក្រុមអ្នករៀបរៀង និងចងក្រងសៀវភៅ**

# គោលបំណង និងរចនាសម្ព័ន្ធសៀវភៅ

## ១. គោលបំណងសៀវភៅ

សៀវភៅនេះជាឧបករណ៍ជំនួយមួយ ដែលត្រូវបានរៀបរៀងឡើងក្នុងគោលបំណង៖

១. ជួយដល់ដំណើរការបង្ហាញព័ត៌មានអំពីកិច្ចលទ្ធកម្មរបស់អាជ្ញាធរក្រុង ស្រុក ខណ្ឌ និង

២. បង្ហាញព័ត៌មានដែលមានសារៈសំខាន់ដល់ពលរដ្ឋ ឬអ្នកអនុវត្តគម្រោងអំពីកិច្ចលទ្ធកម្ម ដើម្បីជំរុញឲ្យដំណើរការកិច្ចលទ្ធកម្មមានតម្លាភាព និងគណនេយ្យភាពក្នុងតំបន់របស់ពួកគាត់ ឲ្យកាន់តែមានភាពប្រសើរឡើង។

## ២. រចនាសម្ព័ន្ធសៀវភៅ

សៀវភៅស្តីពី ការផ្សព្វផ្សាយព័ត៌មានជាធារណៈអំពីលទ្ធកម្ម នេះត្រូវបានរៀបរៀង ជាពីរភាសា គឺជាភាសាខ្មែរ និងភាសាអង់គ្លេស ហើយខ្លឹមសារសំខាន់ៗនៅក្នុងសៀវភៅនេះត្រូវ បានចែកជាបីផ្នែកធំៗ គឺ ៖

**ផ្នែកទី១** ៖ និយាយអំពីលទ្ធកម្ម និងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ នៅក្នុង ប្រទេសកម្ពុជា

**ផ្នែកទី ២**៖ និយាយពីការផ្សព្វផ្សាយព័តិអំពីកិច្ចលទ្ធកម្មសាធារណៈ

**ផ្នែកទី ៣**៖ ការអនុវត្ត

# មាតិកា

## ផ្នែកទី១ ៖ សេចក្តីផ្តើម ទំព័រ


១.លទ្ធកម្មសាធារណៈនៅកម្ពុជា ........................................១

ក. ប្រភេទលទ្ធកម្ម........................................២

ខ. វិធីសាស្រ្តលទ្ធកម្ម........................................៤

គ. ការឃុបឃិតស៊ីគ្រលំគ្នាក្នុងការដេញថ្លៃ........................................៧

ឃ.ចំណុចសំខាន់ពីរដែលប្រធានស្ថាប័ន រដ្ឋាភិបាល និងពលរដ្ឋគួរពិចារណា...៧

ង. ទម្រង់នៃអំពើពុករលួយក្នុងការធ្វើលទ្ធកម្ម........................................៨

២. ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ........................................១២

ក. ទស្សនៈទាន ........................................១២

ខ. គោលបំណង........................................១៣

គ. សារៈប្រយោជន៍ ........................................១៣

- សម្រាប់រដ្ឋ........................................១៤
- សម្រាប់ពលរដ្ឋ ........................................១៤
- សម្រាប់អង្គការក្រៅរដ្ឋាភិបាល ........................................១៤


## ផ្នែកទី២ ៖ ការផ្សព្វផ្សាយព័ត៌មានអំពីកិច្ចលទ្ធកម្មសាធារណៈ


១. កិច្ចលទ្ធកម្មសម្រាប់ការដេញថ្លៃជាសាធារណៈ ........................................១៥

ក. មុនការដេញថ្លៃ (រៀបចំឯកសារដេញថ្លៃ ប្រកាសព័ត៌មាន បំពេញសំណើដេញថ្លៃ ) ........................................១៥

ខ. ពេលដេញថ្លៃ (ការដាក់សំណើដេញថ្លៃ ការបើកសំណើ ដេញថ្លៃ )........១៨

គ. ការអនុវត្តគម្រោង (ការដោះស្រាយការតវ៉ា ការតាមដានការអនុវត្ត និងការវាយតំលៃ) ....................២០

**២.ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ....................២២**

ក. ការផ្សព្វផ្សាយព័ត៌មានអំពីលទ្ធកម្មសាធារណៈរបស់អាជ្ញាធរ ....................២២

ខ. ការទទួល ឬស្វែងរកព័ត៌មានអំពីលទ្ធកម្មសាធារណៈ ....................២៣

## ផ្នែកទី៣៖ ការអនុវត្ត

ក.បទពិសោធន៍របស់សង្គមស៊ីវិលក្នុងការអនុវត្តការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ....................២៥

ខ.ចំណុចត្រូវចងចាំ នៅពេលអនុវត្តការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ...២៥

គ.មេរៀនជាបទពិសោធន៍....................២៧

ឃ. ឧទាហរណ៍ខ្លះៗនៃការអនុវត្តគម្រោងក្នុងខេត្តកំពង់ធំចំពោះការផ្សព្វផ្សាយព័ត៌មាន ....................២៨

# និយមន័យពាក្យបច្ចេកទេសប្រើក្នុងកិច្ចលទ្ធកម្ម

បច្ចេកសព្ទ ឬ វាក្យសព្ទទាំងឡាយសម្រាប់គោលបំណងនៃបទប្បញ្ញត្តិ មានអត្ថន័យដូចខាងក្រោម៖

| | |
|---|---|
| សំណើដេញថ្លៃ | សំដៅដល់សំណុំឯកសារ រួមមាន ឯកសារដេញថ្លៃដែលបានបំពេញ ដោយអ្នកដេញថ្លៃ និងឯកសារភ្ជាប់មួយចំនួនទៀត ដូចមានតម្រូវក្នុង ឯកសារដេញថ្លៃ ដែលអ្នកដេញថ្លៃបានដាក់នៅស្ថាប័នអនុវត្តលទ្ធកម្ម សម្រាប់គោលបំណងផ្គត់ផ្គង់ទំនិញ ទទួលការសំណង់ ផ្តល់សេវាកម្ម ឬសេវាទីប្រឹក្សា។ |
| ប្រាក់កក់ធានាការដេញថ្លៃ | ជាប្រាក់ធានាដែលអ្នកដេញថ្លៃត្រូវកក់មុននឹងចូលរួមការដេញថ្លៃ ដើម្បី ធានាថាអ្នកដេញថ្លៃឈ្នះនឹងទទួលយកកិច្ចសន្យា និងចុះកិច្ចសន្យាជាមួយ រដ្ឋបាលក្រុង ស្រុក ខណ្ឌ ស្របតាមពេលវេលាដែលបានកំណត់នៅក្នុងការ ជូនដំណឹងស្តីពីការប្រគល់កិច្ចសន្យា។ |
| អ្នកដេញថ្លៃ | សំដៅដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្ម របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងបានដាក់សំណើដេញថ្លៃ ឬ សំណើបញ្ជាក់ ពីចំណាប់អារម្មណ៍។ |
| ការដេញថ្លៃ | សំដៅដល់ដំណើការលទ្ធកម្ម ដែលសំណើដេញថ្លៃត្រូវបានដាក់ទទួល និង វាយតំលៃ សម្រាប់គោលបំណងប្រគល់កិច្ចសន្យា។ |
| ឯកសារដេញថ្លៃ | សំដៅដល់សំណុំឯកសារ ដែលអង្គភាពលទ្ធកម្ម បានរៀបចំ និងផ្តល់ជាដំបូង ទៅឲ្យអ្នកដេញថ្លៃ ដើម្បីប្រើសម្រាប់រៀបចំសំណើដេញថ្លៃ ដែលរួមមាន ពាក្យសុំដេញថ្លៃ សេចក្តីអញ្ជើញឲ្យចូលរួមដេញថ្លៃ ការស្នើឲ្យដាក់សំណើ សេចក្តីអញ្ជើញឲ្យចូលរួមក្នុងការកំណត់បុរេលក្ខណសម្បត្តិ សេចក្តីណែនាំ ចំពោះអ្នកដេញថ្លៃ លក្ខណៈបច្ចេកទេស ទំហំការងារ ល័ក្ខខ័ណ្ឌយោង និងល័ក្ខខ័ណ្ឌ |

| | |
|---|---|
| | កិច្ចសន្យា។ |
| ទីប្រឹក្សា | សំដៅដល់ទីប្រឹក្សាឯកជន ឬ ក្រុមហ៊ុនទីប្រឹក្សាដែលមានមុខរបរផ្តល់សេវា ផ្នែកបញ្ញា។ |
| សេវាទីប្រឹក្សា | សំដៅដល់សេវាជំនាញការដែលផ្តល់ដោយក្រុមហ៊ុនទីប្រឹក្សា ឬ ទីប្រឹក្សា ឯកជន ដែលពាក់ព័ន្ធគម្រោងណាមួយ ឬសម្រាប់ពង្រឹងពង្រីកស្ថាប័ន ឬ បង្កើនសមត្ថភាព។ |
| កិច្ចសន្យា | ជាកិច្ចព្រមព្រៀងរវាងរដ្ឋបាល ក្រុង ស្រុក ខណ្ឌ ជាមួយនឹងអ្នកផ្គត់ផ្គង់ទំនិញ អ្នកទទួលការសំណង់ អ្នកផ្តល់សេវាកម្ម ឬ ទីប្រឹក្សា ដើម្បីអនុវត្តការ ផ្គត់ផ្គង់ទំនិញ សំណង់ ផ្តល់សេវាកម្ម ឬ ទីប្រឹក្សា។ |
| ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា | ជាប្រាក់ធានា ដែលអ្នកដេញថ្លៃឈ្នះបានកក់ ដើម្បីធានាការបំពេញកាតព្វកិច្ច របស់ខ្លួនត្រឹមត្រូវតាមល័ក្ខខ័ណ្ឌកិច្ចសន្យា។ ប្រាក់កក់ធានានេះ នឹងត្រូវ រឹបអូសដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ ក្នុងករណីដែលអ្នកដេញថ្លៃឈ្នះ ខកខានពុំបានបំពេញនូវការតព្វកិច្ចរបស់ខ្លួនតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា។ |
| ទំនិញ | សំដៅដល់វត្ថុរាវ រឹង ឬជាឧស្ម័នដែលមានតម្លៃ ឬផលប្រយោជន៍សេដ្ឋកិច្ច ដូចជាគ្រឿងចក្រ ឧបករណ៍ សម្ភារៈ គ្រឿងឧបភោគបរិភោគ ឱសថ និងផលិតផលផ្សេងៗ រួមទាំងអគ្គិសនីផងដែរ។ |
| សំណង់ | សំដៅដល់រាល់សកម្មភាពដែលពាក់ព័ន្ធ នឹងការងារសាងសង់ ការងារ ជួសជុល ការធ្វើឡើងជាថ្មី ការដំឡើង ការជីក ការបូម និងការងារ ប្រហាក់ ប្រហែលដែលបង្កើតឲ្យមានការប្រើប្រាស់កម្លាំងពលកម្ម គ្រឿងម៉ាស៊ីន បរិក្ខា និងបច្ចេកវិទ្យា។ |
| លទ្ធកម្ម | សំដៅដល់ការទិញ ឬរកបាននូវនូវទំនិញ សំណង់ សេវាកម្ម ឬ សេវាទីប្រឹក្សា តាមរយៈវិធីសាស្ត្រ ដូចដែលបានកំណត់ក្នុងបទ |

| | |
|---|---|
| | បញ្ញត្តិនេះ។ |
| កិច្ចលទ្ធកម្ម | សំដៅដល់ដំណើរការកិច្ចលទ្ធកម្ម ចាប់ពីពេលរៀបចំឯកសារដេញថ្លៃ រហូតដល់ពេលទទួលបានទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សា។ |
| សេវាកម្ម | សំដៅដល់សកម្មភាព ដែលពាក់ព័ន្ធ នឹងការប្រើប្រាស់កម្លាំងមនុស្ស គ្រឿងបរិក្ខា និងបច្ចេកវិទ្យាដែលនាំមកនូវប្រយោជន៍រដ្ឋបាលក្រុង ស្រុក ខណ្ឌ ប៉ុន្តែមិនបានរាប់បញ្ចូលការងារសាងសង់ និងសេវាទីប្រឹក្សាទេ។ |
| អង្គភាពប្រើប្រាស់ | ជាអង្គភាព ឬ ការិយាល័យរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលស្នើ កិច្ចលទ្ធកម្ម។ |

# ផ្នែកទី១ ៖ សេចក្ដីផ្ដើម

## ១.លទ្ធកម្មសាធារណៈនៅកម្ពុជា

កិច្ចលទ្ធកម្មសាធារណៈ មានន័យថា ជាការជ្រើសរើសអ្នកទទួលការ ឬអ្នកផ្ដល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ និងការចុះកិច្ចសន្យាច្បាស់លាស់មួយអំពីការងារដែលពួកគេត្រូវធ្វើ ពេលវេលា ដែលត្រូវអនុវត្ត តម្លៃ និងល័ក្ខខ័ណ្ឌចាំបាច់ផ្សេងៗទៀត។ ដំណើការលទ្ធកម្ម មានគោលការណ៍ ចំបង ៣ យ៉ាងដែលត្រូវអនុវត្តគឺ ៖

1. លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សំភារៈ និងការផ្ដល់សេវាកម្ម ត្រូវអនុវត្ត ក្នុងលក្ខណៈមួយដែលមានតម្លាភាព និងសន្សំសំចៃបំផុត តាមដែលអាចធ្វើទៅបាន ដោយធានាគុណភាព ។
2. អ្នកផ្គត់ផ្គង់ និងអ្នកទទួលការត្រូវបានផ្ដល់ឱកាសស្មើៗគ្នា ដើម្បីចូលរួមនៅក្នុងការដេញថ្លៃ ក្រោមល័ក្ខខ័ណ្ឌត្រឹមត្រូវនិងស្មើភាព ។
3. លទ្ធផលនៃការដេញថ្លៃត្រូវផ្សព្វផ្សាយជាសាធារណៈ។

តម្លាភាព មានសារៈសំខាន់ណាស់ នៅក្នុងប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ។ តម្លាភាព មិនគ្រាន់តែមានន័យថា នីតិវិធីទាំងឡាយត្រូវបានធ្វើត្រឹមត្រូវទាំងអស់ប៉ុណ្ណោះទេ ប៉ុន្តែវាមាន ន័យសំខាន់ជាងនេះទៅទៀតនោះ គឺប្រជាពលរដ្ឋគ្រប់រូបអាចមើលឃើញ និងដឹងពិតប្រាកដថា នីតិវិធីទាំងឡាយនោះត្រូវបានគេគោរព និងធ្វើតាមយ៉ាងត្រឹមត្រូវ។

ថវិកាដែលក្រុមប្រឹក្សាឃុំ សង្កាត់ចាយវាយ គឺជាថវិកាដែលបានមកពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់។ ដូច្នេះ ប្រជាពលរដ្ឋមានសិទ្ធិក្នុងការដឹងឮ នូវអ្វីៗដែលក្រុមប្រឹក្សាឃុំ សង្កាត់ធ្វើ និង ការចំណាយនានារបស់ក្រុមប្រឹក្សា។ ប្រសិនបើយើងអនុវត្តនីតិវិធីលទ្ធកម្មដែលនៅពេលប្រជុំ បើកសំណើដេញថ្លៃ មានតែគណៈកម្មការ៣ រូបប៉ុណ្ណោះ ដែលចូលរួមបើកសំណើដេញថ្លៃ ហើយសម្រេចផ្ដល់កិច្ចសន្យាឲ្យទៅអ្នកទទួលការម្នាក់ដែលមានតម្លៃការដេញថ្លៃទៀបជាងគេ។ លទ្ធផលនៃការដេញថ្លៃនេះមិនត្រូវបានផ្សព្វផ្សាយជាសារធារណៈទេ។ តម្លៃនេះវានឹងដូចគ្នា ទៅនឹងតម្លៃ ដែលអនុវត្តតាមនីតិវិធីលទ្ធកម្ម ដែលមានការចូលរួម និងផ្សព្វផ្សាយជាធារណៈដែរ។ ប៉ុន្តែក្នុង

ករណីនេះ គ្មានអ្នកណាម្នាក់ដឹងថា តើមូលហេតុអ្វីដែលត្រូវជ្រើសរើសអ្នកទទួលការនេះ ហើយមូលហេតុអ្វីដែលមិនជ្រើសរើសអ្នកទទួលការដទៃផ្សេងទៀត។ គ្មានអ្នកណាម្នាក់ដឹងទេថា តើតម្លៃនោះជាតម្លៃដែលទៀបជាងគេមែន ឬមិនមែន ដូច្នេះក្នុងករណីនេះគ្មានតម្លាភាពទេ។

ឆ្នាំ១៩៩៥ គឺជាឆ្នាំមួយដ៏សំខាន់សម្រាប់ច្បាប់លទ្ធកម្មសាធារណៈក្នុងប្រទេសកម្ពុជា។ ធនាគារអភិវឌ្ឍន៍អាស៊ី បានផ្ដល់ថវិកាគាំទ្រគម្រោងដែលមានលទ្ធផលនៅក្នុងច្បាប់លទ្ធកម្ម សាធារណៈមួយចំនួនក្នុងប្រទេសកម្ពុជា និយតកម្ម និងស្ថាប័នរបស់រដ្ឋាភិបាល។ ជាការពិតណាស់ សារៈសំខាន់នៃដំណើរការលទ្ធកម្មសាធារណៈដែលប្រកបដោយតម្លាភាព គឺមានភាពចាំបាច់ចំពោះការអភិវឌ្ឍរយៈពេលខ្លី និងរយៈពេលវែង ក្នុងប្រទេសកម្ពុជាដែលជាទីផ្សារសេដ្ឋកិច្ចមួយ។ "អនុក្រឹត្យគ្រប់គ្រងលទ្ធកម្មសាធារណៈក្នុងព្រះរាជាណាចក្រកម្ពុជា" ដែលត្រូវបានប្រកាសជាសាធារណៈកាលពីឆ្នាំ ១៩៩៥ គឺជាឯកសារសំខាន់នៅក្នុងវិធាននៃច្បាប់ និយតកម្ម និង ការណែនាំផ្ទៃក្នុង ដែលបង្កើតប្រព័ន្ធលទ្ធកម្មសាធារណៈក្នុងប្រទេសកម្ពុជា ហើយអនុក្រឹត្យនោះ មានប្រាំពីរមាតិកា។ អនុក្រឹត្យនោះត្រូវបានព្រាងឡើងក្រោមការជួយជ្រោមជ្រែងពីអ្នកជំនាញ ការអន្តរជាតិ និងអ្នកជំនាញផ្នែកលទ្ធកម្មក្នុងស្រុក ហើយត្រូវបានធ្វើឡើងជាលាយលក្ខអក្សរ ជាឯកសារមួយដែលមានភាពស្របច្បាប់ទាំងស្រុង។ ទោះបីជាយ៉ាងណាក៏ដោយ អនុក្រឹត្យនោះ មានវិធានការណ៍បន្តិចបន្តួចដែលមានការកំណត់អាណត្តិ ដើម្បីធ្វើឲ្យមានតម្លាភាព និងគណនេយ្យភាព ចំពោះមន្ត្រីអ្នកអនុវត្តលទ្ធកម្ម។

### គ.ប្រភេទលទ្ធកម្ម

ក្រុមប្រឹក្សាឃុំ សង្កាត់ នឹងអនុវត្តកិច្ចលទ្ធកម្មចំនួនបីប្រភេទសំខាន់ៗ គឺលទ្ធកម្មការងារ សាងសង់ លទ្ធកម្មការងារសេវាកម្ម និងលទ្ធកម្មទំនិញឬសម្ភារៈ។ លទ្ធផលនៃការធ្វើលទ្ធកម្ម គឺជាកិច្ចសន្យា ដូចជា៖

- លទ្ធផលនៃលទ្ធកម្មការងារសាងសង់ គឺកិច្ចសន្យាការងារសាងសង់

- លទ្ធផលនៃលទ្ធកម្មការងារសេវាកម្ម គឺកិច្ចសន្យាការងារសេវាកម្ម
- លទ្ធផលនៃលទ្ធកម្មសម្ភារៈឬទំនិញ គឺកិច្ចសន្យាសម្ភារៈឬទំនិញ(ឬការបញ្ជាទិញ)។

**១.លទ្ធកម្មការងារសាងសង់** គឺសម្រាប់ការសាងសង់ ការជួសជុល ឬ ការថែទាំហេដ្ឋារចនសម្ព័ន្ធ ឬ អគារនានា។ ជួនកាលកិច្ចសន្យាការងារសាងសង់ ក៏អាចរួមបញ្ចូលផងដែរនូវការផ្គត់ផ្គង់សម្ភារៈ បរិក្ខា ដែលត្រូវបំពាក់ទៅនឹងលទ្ធផលនៃកិច្ចសន្យា (ឧទាហរណ៍ ការសាងសង់សាលារៀនមួយ និងការផ្គត់ផ្គង់គ្រឿងសង្ហារឹម ដូចជា កៅអីក្នុងថ្នាក់រៀន)។កិច្ចសន្យាការងារសាងសង់ត្រូវអនុវត្តដោយអ្នកទទួលការងារសាងសង់។

**២.លទ្ធកម្មការងារសេវាកម្ម** គឺសម្រាប់ផ្តល់សេវាកម្មនានា។ កិច្ចសន្យាការងារសេវាកម្មនេះអាចមានសកម្មភាពនានា ដូចជាអប់រំនិងបណ្តុះបណ្តាល ការរៀបចំក្រុមសហគមន៍ និងការផ្តល់ សេវាផ្នែកកសិកម្មជាដើម។ កិច្ចសន្យាសម្រាប់ការងារធ្វើអង្កេត និងរៀបចំគ្រោងការសម្រាប់ គម្រោងហេដ្ឋារចនាសម្ព័ននានា គឺជាកិច្ចសន្យាការងារសេវាកម្មផងដែរ (សេវាកម្មប្រភេទ នេះហៅថា សេវាវិស្វកម្ម)។ កិច្ចសន្យាការងារសេវាកម្មត្រូវបានអនុវត្តដោយអ្នកទទួលការ ផ្តល់សេវាកម្ម។ កិច្ចសន្យាការងារសេវាកម្មអាចរួមបញ្ចូលទាំងការផ្គត់ផ្គង់ទំនិញ ឬ សម្ភារៈបរិក្ខា នានា និងការសាងសង់តូចតាច ដែលបម្រើឲ្យសកម្មភាពនៃសេវាកម្មទាំងនោះ និងរួមចំណែក ដើម្បីឲ្យសេវាកម្មនោះបានសម្រេចទៅតាមទិសដៅរបស់ខ្លួន។ កិច្ចសន្យាសេវាកម្មត្រូវធ្វើ កិច្ចលទ្ធកម្ម ប្រកបដោយការប្រកួតប្រជែង ដោយផ្តោតសំខាន់ទៅលើតម្លៃនៃការដេញថ្លៃសរុប។

**៣.លទ្ធកម្មសម្ភារៈ ឬ ទំនិញ** ត្រូវបានប្រើប្រាស់សម្រាប់ការទិញទំនិញ ឬសម្ភារៈបរិក្ខានានា។ អ្នកផ្គត់ផ្គង់សម្ភារៈមិនចាំបាច់ធ្វើការងារអ្វីច្រើនទេ គឺគ្រាន់តែផ្គត់ផ្គង់ទំនិញ ឬ សម្ភារៈដល់ ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។ នៅពេលដែលទំនិញ ឬសម្ភារៈត្រូវបានត្រូវបាន ប្រគល់ជូន រួចរាល់ហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការទូទាត់ជូនអ្នកផ្គត់ផ្គង់សម្ភារៈ ហើយការបញ្ជាទិញ ត្រូវបានបញ្ចប់ត្រឹមនេះ ។ ប្រសិនបើមានសកម្មភាព

ណាមួយដែលអ្នកផ្គត់ផ្គង់សម្ភារៈត្រូវធ្វើ បន្ទាប់ពីសម្ភារៈត្រូវបានផ្គត់ផ្គង់រួចហើយនោះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើកិច្ចសន្យាការងារ ឬ កិច្ចសន្យាផ្តល់សេវាកម្មជាមួយអ្នកផ្គត់ផ្គង់។

## ខ.វិធីសាស្រ្តលទ្ធកម្ម

ជាទូទៅមានវិធីសាស្រ្ត ៣យ៉ាងសម្រាប់កិច្ចលទ្ធកម្មក្នុងប្រទេសកម្ពុជា គឺ៖

1. **ការដេញថ្លៃដោយប្រកួតប្រជែងជាចំហ៖**

វិធីសាស្រ្តនេះត្រូវអនុវត្ត សម្រាប់កិច្ចសន្យា ដែលជាចំណាយមូលធនលើការងារអភិវឌ្ឍ មូលដ្ឋាន ដោយមិនគិតពីទំហំទឹកប្រាក់ និងសម្រាប់កិច្ចសន្យាជាចំណាយចរន្តលើការងារ អភិវឌ្ឍ មូលដ្ឋាន និងកិច្ចសន្យាសម្រាប់សកម្មភាពផ្សេងទៀតដែលមានទំហំទឹកប្រាក់ចាប់ពី ២លានរៀល ឡើងទៅ។

2. **ការស្វង់តម្លៃក្នុងស្រុក៖**

វិធីសាស្រ្តនេះត្រូវអនុវត្ត ចំពោះសកម្មភាពអភិវឌ្ឍមូលដ្ឋានដែលជាចំណាយចរន្តហើយមានចំនួនទឹកប្រាក់តិចជាង ២លានរៀល និងក្រៅពីសកម្មភាពអភិវឌ្ឍមូលដ្ឋាន ដែលជាចំណាយមូលធន ហើយមានទំហំទឹកប្រាក់ចាប់ពី ៤០០.០០០រៀល រហូតដល់ទាបជាង ២លានរៀល។

3. **ការទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់** (ការចរចារថ្លៃផ្ទាល់) ៖

វិធីសាស្រ្តនេះត្រូវអនុវត្តចំពោះតែករណីពិសេស ហើយត្រូវមានភស្តុតាង និងឯកសារ ច្បាស់លាស់ដែលមានការអនុញ្ញាតិពីអភិបាលខេត្ត ក្រុងជាមុន នៅពេលដែលមិនអាចអនុវត្តវិធីសាស្រ្តទាំងពីរខាងលើបាន ដូចមានបរិយាយបន្ថែមខាងក្រោម។ វិធីសាស្រ្តនេះក៏អាចអនុវត្ត បានដែរសម្រាប់កិច្ចសន្យាថែទាំជាប្រចាំ ដែលក្រុមប្រឹក្សាឃុំ សង្កាត់សម្រេចចិត្តផ្តល់កិច្ចសន្យានេះ ឲ្យទៅអង្គការ សហគមន៍មូលដ្ឋានជាអ្នកអនុវត្ត។

(**ការបរិយាយបន្ថែម**)៖ ការចុះកិច្ចសន្យាផ្ទាល់ ឬការទិញផ្ទាល់ គឺជាវិធីធ្វើការ

ទាក់ទង ចរចារផ្ទាល់ជាមួយអ្នកផ្គត់ផ្គង់ ឬអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្មតែមួយគត់ ហើយត្រូវបានអនុវត្ត ចំពោះ៖

- ការធ្វើលទ្ធកម្មទំនិញ ឬសេវាកម្ម និងការសាងសង់ ជួសជុលនោះមិនលើសពី ៤០០.០០០រៀល (សម្រាប់សកម្មភាពក្រៅពីអភិវឌ្ឍន៍មូលដ្ឋាន)។
- កិច្ចសន្យាដែលជាចំណាយចរន្តសម្រាប់ការងារអភិវឌ្ឍមូលដ្ឋាន ហើយមានទំហំទឹកប្រាក់ តិចជាង២លានរៀល និងមានគោលបំណងជាក់លាក់ ដើម្បីគាំទ្រកម្មវិធីអភិវឌ្ឍរបស់ សហគមន៍ មូលដ្ឋាន និងត្រូវស្នើសុំឲ្យអង្គការសហគមន៍មូលដ្ឋានអនុវត្តកិច្ចសន្យានេះ។

មេឃុំ ចៅសង្កាត់ អាចស្នើសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីអភិបាលខេត្ត ក្រុង ដើម្បីលើកលែងការធ្វើលទ្ធកម្មតាមលក្ខណៈប្រកួតប្រជែងជាចំហរ និងប្រើជាជំនួសវិញដោយការ ទិញផ្ទាល់ ឬការចុះកិច្ចសន្យាផ្ទាល់ចំពោះករណីដូចខាងក្រោម ដោយមិនគិតពីចំនួនទឹកប្រាក់នៃ ការប្រតិបត្តិការឡើយ៖

- ការធ្វើលទ្ធកម្មទំនិញ សេវាកម្ម និងការងារសាងសង់ដែលមិនអាចរកបានអ្នកទទួលការ អ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់បន្ទាប់ពីបានដំណើការអនុវត្តវិធីសាស្ត្រដេញថ្លៃប្រកួតប្រជែងជា ចំហម្តងរួចមកហើយ។
- ការធ្វើលទ្ធកម្មទំនិញ សេវាកម្ម និងការងារសាងសង់ដែលមានលក្ខណៈបច្ចេកទេសអាច អនុវត្តបានចំពោះអ្នកផ្គត់ផ្គង់ ឬចំពោះអ្នកទទួលការ ឬចំពោះអ្នកផ្តល់សេវាកម្មតែម្នាក់។
- ការធ្វើលទ្ធកម្មទំនិញ សេវាកម្ម និងការងារសាងសង់ ដែលមិនអាចជាកម្មវត្ថុនៃការពន្យា ពេលដោយដំណើការប្រកួតប្រជែងថ្លៃ ពីព្រោះវាមានលក្ខណៈជាបន្ទាន់ដែលតម្រូវតាម កាលៈទេសៈ ហើយមិនបានគ្រោងទុកជាមុន។
- ការធ្វើលទ្ធកម្មទំនិញ សេវាកម្ម និងការងារសាងសង់ដែលតម្រូវឲ្យមានការពង្រីក ឬ ជួសជុលឧបរណ៍ដែលមានស្រាប់។

- ការបញ្ជាទិញថ្មីដដែលមួយទៀត នូវមុខទំនិញដេញថ្លៃរួចមកហើយតាមរយៈការប្រកួតប្រជែង ហើយវាអាចនឹងគ្មានតម្លៃណាទាបជាងនេះទៀតទេ ទោះតាមរយៈការដេញថ្លៃ ណាមួយទៀតណាក៏ដោយ។
- ការទិញដែលត្រូវធ្វើឡើងដោយភ្នាក់ងាររដ្ឋាភិបាលណាផ្សេងទៀត ឬការសាងសង់ដែលត្រូវធ្វើឡើងតាមរយៈស្ថាប័នរដ្ឋ ដោយប្រើប្រាស់មធ្យោបាយផ្ទាល់ក្នុងករណីចាំបាច់ និងបន្ទាន់។

ក្នុងករណីពិសេស ការប្រើវិធីសាស្រ្តលទ្ធកម្មដែលមានតម្លៃកិច្ចសន្យាខុសពីការបរិយាយ ខាងលើនេះ ត្រូវធ្វើការពិនិត្យអំពីករណីដោយឡែកនីមួយៗដោយផ្អែកលើសេចក្តីសម្រេចរបស់ អភិបាលខេត្ត ក្រុង។

ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ សង្កាត់ អាចសម្រេចធ្វើការចរចារថ្លៃ និងចុះកិច្ចសន្យាផ្ទាល់ជាមួយ និងអង្គការ សហគមន៍មូលដ្ឋាន ដើម្បីអនុវត្តកិច្ចសន្យាថែទាំផ្លូវ ឬហេដ្ឋារចនាសម្ព័ន្ធផ្សេងទៀតជាប្រចាំ។ ប្រសិនបើអភិបាលក្រុង អនុញ្ញាតិឲ្យចរចារផ្ទាល់ហើយ មេឃុំ ចៅសង្កាត់ត្រូវរៀបចំ ឯកសារ ដើម្បីធ្វើការចរចារថ្លៃផ្ទាល់នេះ ដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស។ ការរៀបចំឯកសារនេះ គឺស្រដៀងគ្នាទៅនឹងការរៀបចំឯកសារសម្រាប់ការដេញថ្លៃជាធម្មតាដែរ។

បន្ទាប់មក គណៈកម្មការលទ្ធកម្មត្រូវអញ្ជើញអ្នកទទួលការ ឬអ្នកផ្គល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ ណាម្នាក់ឲ្យដាក់សំណើសម្រង់តម្លៃ។ ប្រសិនបើតម្លៃនេះទាបជាងតម្លៃប៉ាន់ស្មាននៃកិច្ចសន្យា គណៈកម្មការលទ្ធកម្មអាចផ្តល់អនុសាសន៍ឲ្យទទួលយកសំណើសម្រង់តម្លៃនោះ។ ប៉ុន្តែ ក្នុងករណី ដែលតម្លៃនោះខ្ពស់ជាងតម្លៃប៉ាន់ស្មាននៃកិច្ចសន្យា គណៈកម្មការលទ្ធកម្មអាចចរចារផ្ទាល់ ជាមួយ អ្នកទទួលការ ឬអ្នកផ្គល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់នោះ ដើម្បីបញ្ចុះតម្លៃកត្រឹមតម្លៃប៉ាន់ស្មានឬទាបជាងនេះ។ ប្រសិនបើការចរចារតម្លៃនេះមិនទទួលជោគជ័យ គណៈកម្មការលទ្ធកម្ម អញ្ជើញ អ្នកទទួលការ ឬអ្នកផ្គល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ណាម្នាក់ឲ្យដាក់សំណើសម្រង់តម្លៃ ហើយអនុវត្ត តាមវិធីដែល

បានរៀបរាប់ខាងលើ។

## គ. ការឃុបឃិតស៊ីគ្រលំគ្នាក្នុងការដេញថ្លៃ

ការឃុបឃិតស៊ីគ្រលំគ្នា មានន័យថា ជាការរៀបចំរវាងអ្នកដេញថ្លៃ និងអ្នកដេញថ្លៃ ២នាក់ ឬច្រើននាក់ដែលរៀបចំឡើងដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិត មិនមានប្រកួត ប្រជែង ឬដើម្បីធ្វើឲ្យមានឥទ្ធិពលទៅលើសកម្មភាពនៃភាគីណាមួយនៅក្នុងដំណើការ លទ្ធកម្ម។ ប្រសិនបើមានការដេញថ្លៃគម្រោងឃុំ សង្កាត់ណាមួយ មានការឃុបឃិត ស៊ីគ្រលំគ្នា គណៈកម្មការលទ្ធកម្មត្រូវប្រកាសលុបចោលការដេញថ្លៃនោះ។ ដូច្នេះបន្ទាប់ពី ការវាយតម្លៃសំណើដេញថ្លៃ និងមុនពេលនៃការប្រកាសលទ្ធផលនៃការដេញថ្លៃ គណៈកម្មការលទ្ធកម្មដោយមានជំនួយពីមន្ត្រីគាំទ្របច្ចេកទេស និងអ្នកសម្របសម្រួលខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវត្រួតពិនិត្យអំពីការឃុបឃិតស៊ីគ្រលំគ្នាក្នុងការដេញថ្លៃ។

សូចនាករនៃការឃុបឃិតស៊ីគ្រលំគ្នា មានការលំបាកក្នុងការកំណត់ និងមានលក្ខណៈខុសៗគ្នា ពីកន្លែងមួយទៅកន្លែងមួយ ដូច្នេះគណៈកម្មការលទ្ធកម្ម និងអ្នកមានភារៈកិច្ច ជួយដល់គណៈកម្មការលទ្ធកម្ម ត្រូវពិភាក្សាគ្នានិងសន្និដ្ឋានអំពីដំណើរការនៃការដេញថ្លៃនីមួយៗ ថាតើដំណើការនៃការដេញថ្លៃ និងលទ្ធផលនៃការដេញថ្លៃនោះមានការ ឃុបឃិត ស៊ីគ្រលំគ្នាដែរ ឬទេ។

## ឃ.ចំណុចសំខាន់ពីរដែលប្រធានស្ថាប័ន រដ្ឋាភិបាល និងពលរដ្ឋគួរពិចារណា

ចំពោះការឃុបឃិតស៊ីគ្រលំគ្នាក្នុងការដេញថ្លៃនោះ មានចំណុចធំៗពីរ ដែលប្រធានគម្រោង រដ្ឋាភិបាល និងប្រជាពលរដ្ឋគ្រប់រូបគួរតែដឹង និងគួរតែធ្វើការពិចារណាទាំងអស់គ្នា ពោលគឺៈ

**ចំណុចទី១** ៖ ទោះជាក្នុងករណីណាក៏ដោយចុះ ការប្រព្រឹត្តអំពើពុករលួយរបស់មន្ត្រីក្រោមឱវាទគឺជារឿងដែលប្រធានស្ថាប័នមិនអាចប្រកែកយកខ្លួនបានឡើយ។ ផ្ទុយទៅវិញ ប្រធានស្ថាប័នមិនត្រឹមតែប្រកែកយករួចខ្លួនប៉ុណ្ណោះទេ តែពេលខ្លះថែមទាំងបាននិយាយការពារកូនចៅដែលប្រព្រឹត្តខុសទៀតផង។ តើពួកគេពិតជាមិនដឹងមែន ឬ

ធ្វើជាមិនដឹង? ទោះបីជាមិនដឹងមែន ក៏គួរតែព្យាយាមយកបញ្ហាទៅពិនិត្យនិងស៊ើបអង្កេតជាបន្ទាន់ដែរ ពីព្រោះអំពើពុករលួយ ចំពោះថវិកាដែលបរទេសជួយសម្រាប់សង្គ្រោះជីវិត ពលរដ្ឋរបស់ខ្លួន ឬក៏អំពើពុករលួយចំពោះថវិការបស់រដ្ឋ គឺជារឿងមិនគួរអត់ឱនជាដាច់ខាត។

**ចំណុចទី២៖** ប្រធានស្ថាប័ននិងមន្ត្រីថ្នាក់លើ គួរតែស្វែងយល់ពីអំពើពុករលួយនៅក្នុងប្រព័ន្ធនៃការដេញថ្លៃគម្រោងនានា ដែលកើតមានតាំងពីយូរមកហើយ។ ជាទូទៅគម្រោងត្រូវបានដាក់ឲ្យដេញថ្លៃជាសាធារណៈនៅចំពោះមុខម្ចាស់ជំនួយ និងមន្ត្រីរដ្ឋាភិបាល ដែលមើលទៅហាក់ដូចជាអ្វីៗប្រព្រឹត្តទៅដោយរលូននិងមានតម្លាភាព។ ប៉ុន្តែនៅក្រោយវាំងនននៃការដេញថ្លៃនេះ គឺការឃុបឃិតគ្នាជាខ្សែសង្វាក់ ប្រទាក់ក្រឡាគ្នាយ៉ាងល្អពោលគឺវាជាការរៀបចំទុកជាមុនទាំងអស់។ តាមពិតគេបានដឹងជាមុនស្រេចទៅហើយថាក្រុមហ៊ុនណាជាអ្នកឈ្នះ។ រីឯក្រុមហ៊ុនផ្សេងទៀតគ្រាន់តែចូលរួមគម្រប់កិច្ចជាថ្នូរនឹងប្រាក់ទឹកតែ ឬ ក្រុមហ៊ុនខ្លះទៀតគ្រាន់តែត្រូវបានគេអនុញ្ញាតឲ្យចូលរួមដើម្បី លម្អឆាកដេញថ្លៃតែប៉ុណ្ណោះ។ មានតែមន្ត្រីពាក់ព័ន្ធ និងក្រុមហ៊ុនអ្នករកស៊ីក្នុងវិស័យទាំងនេះទេដែលបានដឹងច្បាស់អំពីរឿងនេះ។ ល្បែងផ្តិនភ្នែកបែបនេះកើតឡើងក្នុងគ្រប់វិស័យមិនថាតែជាគម្រោងធំៗ ដែលផ្តល់មូលនិធិដោយស្ថាប័នអន្តរជាតិធំៗប៉ុណ្ណោះទេ តែវាក៏កើតមានផងដែរចំពោះគម្រោងដែលផ្តល់ថវិកាដោយរដ្ឋាភិបាល ដូចជាការដេញថ្លៃឡនេសាទ គម្រោងសាងសង់ផ្លូវលំជនបទ និងគម្រោងជាច្រើនទៀតរាប់មិនអស់។ អ្វីដែលម្ចាស់ជំនួយនិងរដ្ឋាភិបាលគិតមិនដល់នោះគឺ តម្លៃត្រូវបានគេត្រូវរ៉ូវគ្នារួចទៅហើយ។

ដូច្នេះនៅក្រោយការដេញថ្លៃនោះ គឺការបែងចែកផលប្រយោជន៍ទៅតាមកិច្ចសន្យា។ ការឃុបឃិតជាខ្សែសង្វាក់ដ៏ធំនេះបានបន្លំភ្នែកម្ចាស់ជំនួយ និង រដ្ឋាភិបាលជាច្រើនឆ្នាំមកហើយ ហើយនេះជាជំនាញដ៏ប៉ិនប្រសប់របស់ជនពុករលួយនៅកម្ពុជា។

## ខ. ទម្រង់នៃអំពើពុករលួយក្នុងការធ្វើលទ្ធកម្ម

នៅក្នុងការធ្វើលទ្ធកម្មគេសង្កេតឃើញថាមានអំពើពុករលួយមួយចំនួន ដែលក្នុងនោះ ប្រភេទនៃអំពើពុករលួយគេអាចសំគាល់បានតាមរយៈចំណុចមួយចំនួនដូច

ខាងក្រោម៖

**ការសូកប៉ាន់៖**

ការចំណាយលុយដ៏ច្រើន សម្រាប់មន្ត្រីរដ្ឋាភិបាល ដើម្បីជាការដោះដូរជាមួយ និងសកម្មភាពដែលខ្លួនចង់ធ្វើនៅតាមក្រសួង ឬ កន្លែងណាមួយ ជាធម្មតាគឺដើម្បីធ្វើឲ្យមានឥទ្ធិពលចំពោះ ការផ្តល់នូវកិច្ចសន្យា របស់រដ្ឋាភិបាល (ចំណាំ៖ រដ្ឋបាលដែលមានលក្ខណៈធូរលុង ឬ មិនម៉ឺងម៉ាត់ ការសូកប៉ាន់គឺត្រូវបានចាត់ទុកថាជាទស្សនៈមួយដាច់ដោយឡែក ដែលចាំបាច់ត្រូវតែធ្វើដើម្បី ទទួលបានអ្វីមួយដែលខ្លួនចង់បានដូចជាការដេញថ្លៃជាដើម)។ ការអនុវត្តបែបនេះគឺជារឿង ដែលសាមញ្ញបំផុតនៅក្នុងកន្លែងខ្លះ ដែលការចំណាយក្រៅផ្លូវការបែបបនេះគឺជាសកម្មភាព ដែលបានរំពឹងទុក ហើយតំលៃនៃការចំណាយទាំងនោះ គឺជាធម្មតាត្រូវបានបង្កើន ទៅលើតំលៃទីផ្សារ។ ក្នុងករណីបែបនេះ "អត្រាទីផ្សារ" ការសូកប៉ាន់ទាំងនោះ គឺជាការអនុវត្តដែលត្រូវបានទទួលយកក្នុងវិស័យពាណិជ្ជកម្ម ដែលមិនមានភាពចាំបាច់ក្នុងការផ្តល់ឲ្យអ្នកផ្តល់សំណូកនូវគុណប្រយោជន៍ទេ ប៉ុន្តែជាការប្រសើរជាងការដែលមិនធ្វើឲ្យការចំណាយនោះមានគុណប្រយោជន៍ សម្រាប់ការធ្វើជំនួញ។ នៅពេលដែលការសូកប៉ាន់ទាំងនោះត្រូវបានបង្កើតជាដំណើរការជាមួយ និងភស្តុតាងដែលជាឯកសារមានតែបន្តិចបន្តួចការការពារគឺពិតជាមានការលំបាកណាស់។

**ឈ្មួលកម្រៃជើងសារ៖** មនុស្សនៅក្នុងកន្លែងមូលដ្ឋានមួយ ឬ ជាមនុស្សដែលត្រូវបានទទួលការអះអាងបញ្ជាក់ថា អ្នកផ្តល់យោបល់ទីបី ដោយក្រុមហ៊ុនបរទេសមួយដើម្បីជាតំណាងក្រុមហ៊ុន ក្នុងទីផ្សារក្នុងស្រុកដើម្បីធ្វើសេចក្តីរាយការណ៍ប្រាប់ក្រុមហ៊ុនបរទេសអំពីឱកាសពាណិជ្ជកម្ម (ដូចជាការស្នើសុំរបស់រដ្ឋាភិបាលនាពេលខាងមុខ) ដើម្បីជាជំនួយដល់ក្រុមហ៊ុនបរទេស ក្នុងការទទួលបាននូវការស្នើសុំរបស់រដ្ឋាភិបាល ដើម្បីជាជំនួយចំពោះការប្រមូលនូវការសងប្រាក់ របស់រដ្ឋាភិបាលនិងដើម្បីផ្តល់នូវ "សេវាពាណិជ្ជកម្មទូទៅ"។ ជាទូទៅ ភ្នាក់ងារនេះប្រើបណ្តាញក្នុងតំបន់របស់ខ្លួនដើម្បីធ្វើ

ការសម្រួលកិច្ចខំប្រឹងប្រែងរបស់ក្រុមបរទេស ដើម្បីឈ្នះកិច្ចសន្យាក្នុងតំបន់ជាធម្មតា ដោយការចំណាយក្រៅផ្លូវការចំពោះ "មនុស្សដែលត្រូវ" តំលៃនៃការសូកប៉ាន់ទាំងនោះ គឺត្រូវបានបង្កើនទៅក្នុងតំលៃ សម្រាប់អ្នកពិគ្រោះយោបល់។ វគ្គនៃការព្រមព្រៀង សម្រាប់ភ្នាក់ងារបែបនេះ (ឬ វគ្គនៃអ្នកយោង) គឺមានភាពមិនច្បាស់លាស់ដែល ក្រុមហ៊ុនបរទេស អាចបញ្ជាក់នូវការមិនដឹងមិនឮចំពោះសកម្មភាពរបស់ភ្នាក់ងារ ឬ អាចនិយាយម្យ៉ាងទៀតថា ភ្នាក់ងារធ្វើអ្វីដែលជាការចាំបាច់ដើម្បីធានាសុវត្ថិភាពពាណិជ្ជកម្ម ខណៈពេលដែល ក្រុមហ៊ុនអាចរក្សាបាននូវការបដិសេធ។

**ក្រុមហ៊ុនឈានមុខ៖** ក្រុមហ៊ុនដែលមន្ត្រីរដ្ឋាភិបាលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុដែលជាហេតុធ្វើឲ្យមន្ត្រីទាំងនោះផ្តល់នូវកិច្ចសន្យា របស់រដ្ឋាភិបាលផ្នែកនៃតំលៃរបស់កិច្ចសន្យា គឺត្រូវបានត្រឡប់ទៅមន្ត្រីពុករលួយ ទាំងដែលជាប្រាក់ចំណេញសម្រាប់ក្រុមហ៊ុន ឬ ពួកគេយកចំណែករបស់តំលៃនៃកិច្ចសន្យា "តំលៃលើស" (តំលៃនៃកិច្ចសន្យាត្រូវបានបំប៉ោង លើសពីការពិត ជាមួយនិងប្រាក់ធានាហានិភ័យដែលជាដំណាងឲ្យការ "កាត់" របស់មន្ត្រីពុករលួយ។ ក្នុងករណីជាច្រើន ក្រុមហ៊ុនឈានមុខគឺមានតែនៅលើក្រដាសប៉ុណ្ណោះ ដូច្នេះនៅ ពេលដែលក្រុមហ៊ុនទាំងនោះត្រូវបានគេផ្តល់កិច្ចសន្យាតំលៃនៃកិច្ចសន្យាទាំងមូលគឺត្រូវបានពុះ ជ្រែកដោយមន្ត្រីពុករលួយ (ដែលគ្រប់គ្រងគណនេយ្យធនាគាររបស់ "សំបកក្រុមហ៊ុន") ហើយគ្មានសេវាកម្មអ្វីដែលបានផ្តល់ឲ្យនោះទេ។ ក្នុងករណីដ៏ទៃទៀត ក្រុមហ៊ុនឈានមុខគឺជាអ្នកចុះ កិច្ចសន្យា បន្ទាប់ដែលអ្នកទទួលកិច្ចសន្យាហើយត្រូវបានគេគាបសង្កត់ក្នុងការជួល។ វាជារឿងដែលសាមញ្ញបំផុតសម្រាប់រដ្ឋាភិបាល ដែលត្រូវការភ្នាក់ងារអន្តរជាតិ ដើម្បីធ្វើកិច្ចសន្យា បន្ទាប់បន្សំចំពោះចំនួនជាក់លាក់នៃតំលៃរបស់កិច្ចសន្យាចំពោះក្រុមហ៊ុនក្នុងស្រុក (ឬ តម្រូវការ នៃសកម្មភាពជាក់លាក់ ដូចជាការសាងសង់ ការធ្វើកិច្ចសន្យាបន្តឲ្យក្រុមហ៊ុនក្នុងស្រុក) ហើយភ្នាក់ងារ កិច្ចសន្យាបរទេសជាញឹកញាប់ត្រូវការជ្រើសរើសពីបញ្ជីនៃ "ការអនុម័តរបស់ រដ្ឋាភិបាល" អ្នកធ្វើកិច្ចសន្យាបន្ទាប់បន្សំក្នុងស្រុក។

**សម្ភារៈនៃការដេញថ្លៃ៖** (ការសម្របសម្រួលចំពោះការស្នើរសុំ)៖ មន្ត្រីរដ្ឋាភិបាលត្រូវធ្វើឲ្យប្រាកដថា ក្រុមហ៊ុនជាក់លាក់ណាមួយឈ្នះកិច្ចសន្យាការដេញថ្លៃរបស់ក្រុមហ៊ុននេះ គឺត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដេញថ្លៃទាំងនោះ ដែលកំពុងចូលរួមក្នុង (ឬ មានបំណងចូលរួមក្នុង) ការស្នើសុំ។ មន្ត្រីទាំងនោះធ្វើការដើម្បីទទួលបានប្រាក់ចំណេញតាមវិធីខ្លះៗ ដូចជាតាមរយៈ ការធ្វើឲ្យក្រុមហ៊ុនឈ្នះកិច្ចសន្យាជាដើម។ ប្រសិនបើកិច្ចសន្យាត្រូវបានស្នើរសុំជាមួយនឹងការ ដេញថ្លៃជាលក្ខណៈបើកចំហរ មន្ត្រីត្រូវតែជួលប្រភេទនៃគម្រោងខ្លះ ដើម្បីធ្វើឲ្យប្រាកដថាបាន សម្រេចនូវលទ្ធផលដែលប្រថ្នាចង់បាន។ គ្រប់មន្ត្រីដែលពាក់ព័ន្ធទាំងអស់បានរួមគំនិត ជាលក្ខណៈក្រៅផ្លូវការក្នុងដំណើរការនៃការវាយតំលៃការដេញថ្លៃ ចំពោះការយល់ព្រមជ្រើសរើស អ្នកដេញថ្លៃជាក់លាក់ណាមួយ។ ការសម្របសម្រួលជាក់លាក់ គឺជាការបន្ថែមបន្ថយ ដើម្បីសុំការអនុគ្រោះពីអ្នកដេញថ្លៃ។ អ្នកដេញថ្លៃត្រូវបានគេផ្តល់ឲ្យនូវពត៌មានផ្ទៃក្នុង ដូច្នេះពួកគេអាច ដឹងពីគន្លឹះខ្លះៗលើការដេញថ្លៃដើម្បីឲ្យបានទទួលជោគជ័យ។ ក្រុមហ៊ុនមានចេតនា "ក្នុងការយក តំលៃថោក" ការដេញថ្លៃរបស់ពួកគេមានតំលៃទៀបជាងអ្នកប្រកួតប្រជែងដ៏ទៃទៀត ជាមួយនឹង ការយល់ព្រមថា បន្ទាប់ពីពួកគេឈ្នះការដេញថ្លៃរាល់ផ្នែកនៃហិរញ្ញវត្ថុទាំងអស់អាចសើរើពិនិត្យឡើងវិញបាន។

**ក្រុមហ៊ុនដែលកាន់កាប់ដោយមន្ត្រីរដ្ឋ៖** ពាណិជ្ជកម្មក្នុងស្រុកដែលប្រកួតប្រជែងសម្រាប់កិច្ចសន្យា (ហើយតែងតែឈ្នះ) របស់រដ្ឋាភិបាល ប៉ុន្តែមានការកាន់កាប់ដោយបើកចំហរ និង/ឬ ដំណើរការដោយគ្រួសារណាមួយជាលក្ខណៈពេញមុខ ជាមួយនឹងទំនាក់ទំនងជិតស្និទ្ធ ជាមួយនឹងរដ្ឋភិបាល ឬ របបដឹកនាំ។ ក្រុមហ៊ុនបែបនេះតែងតែពេញចិត្តក្នុងការកាន់កាប់អំណាចផ្តាច់មុខ ជាពិសេស ក្នុងវិស័យពាណិជ្ជកម្ម ដែលពាក់ព័ន្ធជាមួយនឹងកិច្ចសន្យារបស់រដ្ឋភិបាល។ វាមិនមែនជារឿងមិនធម្មតាទេសម្រាប់រដ្ឋាភិបាល ក្នុងប្រទេសបែបនេះ ក្នុងការស្នើរសុំថវិកា ពីប្រទេសអ្នកផ្តល់ជំនួយសម្រាប់គម្រោងអភិវឌ្ឍ ដែលមានការពាក់ព័ន្ធជាមួយសេវា និងសកម្មភាពរបស់មន្ត្រីដែលពាក់

ព័ន្ធជាមួយនឹងគណបក្សនយោបាយផ្តល់ឲ្យ→ ឱកាសជាច្រើន សម្រាប់ក្រុមហ៊ុនបែប នេះ ដើម្បីទទួលបានកិច្ចសន្យាផ្តល់ជំនួយរបស់រដ្ឋាភិបាល។ បាតុភូតនេះ គឺត្រូវបានគេ ស្គាល់ថាជា ″ការប្រើប្រាស់ថវិការរបស់រដ្ឋាភិបាលសម្រាប់គម្រោងអភិវឌ្ឍដើម្បីឈ្នះ ការបោះឆ្នោត″ នៃគម្រោងអភិវឌ្ឍមន្ត្រីរដ្ឋាភិបាលស្នើរគម្រោងអភិវឌ្ឍដែលនឹងផ្តល់ ប្រយោជន៍ ជាក់លាក់ដល់ក្រុមហ៊ុនក្នុងស្រុក (ឧ. បងប្រុសរបស់ប្រធាធិបតី កាន់កាប់ ក្រុមហ៊ុនសាងសង់ផ្លូវថ្នល់ ដូច្នេះយុទ្ធសាស្ត្រអភិវឌ្ឍប្រទេសនឹងមានការពាក់ព័ន្ធ ជាមួយនិងគម្រោងអភិវឌ្ឍផ្លូវជាច្រើន)។

**ការលួចគណនីរបស់រដ្ឋាភិបាល៖** មន្ត្រីសាធារណៈជាធម្មតាសរសេរ ការពិនិត្យ របស់រដ្ឋាភិបាល សម្រាប់ខ្លួនពួកគេ (ឬចំពោះមិត្តភ័ក្តដែលស្និតស្នាល) ជា ទូទៅគឺអាស្រ័យទៅលើ វិក័យប័ត្តបន្លំ។ ការចំណាយសម្រាប់សំភារៈប្រើប្រាស់ក្នុង ការិយាល័យគឺជាបញ្ហាប្រឈមសំខាន់ សម្រាប់ការលួចបែបនេះ។

## ២. ការផ្សព្វផ្សាយព័ត៌មានជាធារណៈ

### ក. ទស្សនទាន

ទស្សនៈទានរបស់ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ គឺជាចេតនា និងឆន្ទៈ របស់ រដ្ឋាភិបាលក្នុងការផ្សព្វផ្សាយព័ត៌មានទាំងឡាយ ដែលសាធារណៈជនមិនធ្លាប់ ដឹងពីមុន។ វិធាននៃ ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ បានចែងពីព័ត៌មានដែលត្រូវ ផ្សព្វផ្សាយ និងព័ត៌មានដែល មិនត្រូវផ្សព្វផ្សាយ។ ឧទាហរណ៍ ព័ត៌មានដែលអាចគំរាម កំហែងដល់សន្តិសុខជាតិ បូរណៈភាពទឹកដី ឬអធិបតេយ្យភាពរបស់ជាតិ មិនត្រូវ ផ្សព្វផ្សាយជាសាធារណៈនោះទេ ដូចជាព័ត៌មាន អំពីកងទ័ព។

ទស្សនៈទាននៃការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ក៏ទទួលស្គាល់ថា ព័ត៌មានខ្លះមាន សារៈប្រយោជន៍ និងសំខាន់សម្រាប់សមាគម ហើយគួរតែត្រូវបាន ផ្សព្វផ្សាយឲ្យបានទូលំទូលាយ និងយ៉ាងទៀងទាត់។ ដូច្នេះ អាជ្ញាធរក្រុង ស្រុក ខណ្ឌ គួរតែព្យាយាមផ្សព្វផ្សាយព័ត៌មាន ដល់សាធារណៈជនឲ្យបានច្រើន ដើម្បីបង្កើតតម្លា ភាព និងគណនេយ្យភាពក្នុងការបំពេញ មុខងារ របស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ តាម

រយៈការផ្សព្វផ្សាយព័ត៌មាន ដែលបង្ហាញពីអភិបាលកិច្ចក្រុង ស្រុក ខណ្ឌ ដូចជា បុគ្គលិក រចនាសម្ព័ន្ធរដ្ឋបាល ហិរញ្ញវត្ថុ និងការប្រតិបត្តិនានា ជាពិសេស អំពីលទ្ធកម្មសាធារណៈ។

## ខ. គោលបំណង

ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ នឹងជួយឲ្យសម្រេចបានគោលបំណងដូចខាងក្រោម៖

- បង្កើតឲ្យមានតម្លាភាព និងគណនេយ្យភាពក្នុងការបំពេញមុខងាររបស់អាជ្ញាធរ សាធារណៈ (PAs) ក្នុងកិច្ចលទ្ធកម្មសាធារណៈ ឲ្យកាន់តែមានភាពប្រសើរឡើង។
- ធ្វើឲ្យពលរដ្ឋដឹងពីតួនាទីរបស់ខ្លួន និងតួនាទីរបស់អាជ្ញាធរសាធារណៈ និងធ្វើឲ្យអាជ្ញាធរសាធារណៈប្រើប្រាស់ឲ្យមានប្រសិទ្ធភាពនូវទម្រង់ចូលរួមនានា ដើម្បីឲ្យមានឥទ្ធិពល ទៅលើគោលនយោបាយ។
- ពលរដ្ឋអាចចូលរួមត្រួតពិនិត្យ និងតាមដានកិច្ចលទ្ធកម្មសាធារណៈ និងអាចរើសបានអ្នកម៉ៅការដែលល្អពិតប្រាកដ។
- ជួយពលរដ្ឋ ប្រើប្រាស់វេទិកាចូលរួមសម្រាប់ផ្លាស់ប្តូរគោលនយោបាយយ៉ាងមានប្រសិទ្ធភាព។
- អង្គការសង្គមស៊ីវិល ដែលមានបំណងឲ្យកិច្ចលទ្ធកម្មសាធារណៈរបស់អាជ្ញាធរមាន
- ភាពល្អប្រសើរ អាចប្រើប្រាស់ព័ត៌មានដែលបង្ហាញក្នុងសៀវភៅនេះដើម្បីអនុវត្ត គម្រោង អំពីលទ្ធកម្ម។
- អាចធ្វើការប្រៀបធៀបពីភាពខុសគ្នារវាងកន្លែង ដែលមានការផ្សព្វផ្សាយព័ត៌មានយ៉ាងទៀងទាត់ និងកន្លែងដែលមិនមានការផ្សព្វផ្សាយព័ត៌មាន។

## គ. សារៈប្រយោជន៍

ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ នឹងផ្តល់ប្រយោជន៍យ៉ាងច្រើនដល់

ពលរដ្ឋ រដ្ឋ និង អង្គការក្រៅរដ្ឋាភិបាល។

**១) សម្រាប់រដ្ឋ**

- ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ កាត់បន្ថយពេលវេលា ថវិកានិងការងាររបស់អាជ្ញាធរ ក្នុងការផ្តល់ព័ត៌មានដល់សាធារណៈជនអំពីលទ្ធកម្មសាធារណៈ។
- កាត់បន្ថយបន្ទុកផ្នែករដ្ឋបាលរបស់រដ្ឋាភិបាល ក្នុងការផ្តល់ព័ត៌មានចំពោះការស្នើសុំរបស់ ពលរដ្ឋ ដូចច្បាប់ស្តីពីសិទ្ធិទទួលព័ត៌មាន បានចែង។

**២) សម្រាប់ពលរដ្ឋ**

- ធ្វើឲ្យពលរដ្ឋទទួលបានព័ត៌មានត្រឹមត្រូវតាមច្បាប់មានប្រយោជន៍និងសំខាន់។
- ជួយឲ្យពលរដ្ឋដឹងពីរបៀប និងវិធីទទួលបានព័ត៌មាន។
- ផ្តល់ព័ត៌មានដល់សាធារណៈជនយ៉ាងលម្អិតស្តីពីអាជ្ញាធរសាធារណៈ (PAs) ពីដំណើរការ ការសំរេចចិត្ត និងការធ្វើលទ្ធកម្មរបស់អាជ្ញាធរសារធារណៈឲ្យកាន់តែមានប្រសិទ្ធភាព។

**៣) សម្រាប់អង្គការក្រៅរដ្ឋាភិបាល**

- អាចចូលរួមក្នុងការធ្វើឲ្យកិច្ចលទ្ធសាធារណៈរបស់អាជ្ញាធរក្រុង ស្រុក ខណ្ឌមានភាព ប្រសើរឡើង តាមរយៈការអនុវត្តគម្រោងអំពីលទ្ធកម្ម។

## ផ្នែកទី២ ៖ ការផ្សព្វផ្សាយព័ត៌មានអំពីកិច្ចលទ្ធកម្មសាធារណៈ

### ១. កិច្ចលទ្ធកម្មសម្រាប់ការដេញថ្លៃជាសាធារណៈ

### ក. មុនការដេញថ្លៃ( រៀបចំឯកសារដេញថ្លៃ ប្រកាសព័ត៌មាន បំពេញសំណើដេញថ្លៃ )

<u>រៀបចំឯកសារដេញថ្លៃ</u> ៖ សម្រាប់មុនពេលនៃការធ្វើលទ្ធកម្ម គឺគេត្រូវធ្វើការរៀបចំឯកសារ ជាមុនសិន ហើយរបៀបនៃការរៀបចំឯកសារនោះត្រូវបានបែងចែកជាដំណាក់កាលដូចខាងក្រោម៖

- អង្គភាពលទ្ធកម្មក្រុង ស្រុក ខណ្ឌត្រូវរៀបចំឯកសារដេញថ្លៃ ដើម្បីធ្វើការដាក់ជូនគណៈកម្មាធិការលទ្ធកម្ម ក្រុង ស្រុក ខណ្ឌ ពិនិត្យ និងសម្រេច។
- អភិបាលក្រុង ស្រុក ខណ្ឌ ត្រូវដាក់ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវឯកសារដេញថ្លៃ ដើម្បីស្នើសុំទិដ្ឋាកាយល់ព្រម ចំពោះលទ្ធកម្មទាំងឡាយដែលត្រូវពិនិត្យ និងសម្រេច ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ឯកសារដេញថ្លៃមានគោលបំណងផ្តល់ពត៌មាន ចាំបាច់នានាដល់អ្នកដេញថ្លៃ ដើម្បីឲ្យអ្នកដេញថ្លៃអាចរៀបចំសំណើរដេញថ្លៃឲ្យមានលក្ខណៈពេញលេញ។ ឯកសារទាំងនោះរួមមាន ៖
    - សេចក្តីណែនាំចំពោះអ្នកដេញថ្លៃ
    - ល័ក្ខខ័ណ្ឌនៃកិច្ចសន្យា
    - ការបរិយាយលក្ខណៈ បច្ចេកទេសលម្អិត
    - គំនូសប្លង់បច្ចេកទេស ឬ ប៉ាន់គំរូ ឬ កាតាឡុក
    - ទម្រង់ពាក្យសុំដេញថ្លៃ
    - ទម្រង់បញ្ជីប៉ាន់តំលៃ ឬ ទម្រង់តារាងតំលៃ
    - សេចក្តីប្រកាសក្រមសីលធម៌លទ្ធកម្ម។

<u>ប្រកាសព័ត៌មាន</u>៖ បន្ទាប់ពីការរៀបចំឯកសារទៅតាមច្បាប់ ពោលគឺបន្ទាប់ពីអង្គភាពលទ្ធកម្មក្រុង ស្រុក ខណ្ឌ បានរៀបចំឯកសារដេញថ្លៃ ដើម្បីដាក់សុំការពិនិត្យ និងសម្រេចពីគណៈកម្មការ លទ្ធកម្មរួចហើយ អង្គភាពលទ្ធកម្មត្រូវជូនដំណឹងស្តីពីការដេញថ្លៃដល់សាធារណៈជន ឲ្យបាន ជ្រាប ។ អង្គភាពលទ្ធកម្មត្រូវរៀបចំសេចក្តីជូន

ដំណឹងស្តីពីការដេញថ្លៃ ដើម្បីដាក់ជូនអភិបាលក្រុង ស្រុក ខណ្ឌ ពិនិត្យ និង ចុះហត្ថលេខា ហើយត្រូវផ្សព្វផ្សាយសេចក្តីជូនដំណឹងនេះឲ្យបាន ទូលំទូលាយជាសាធារណៈ ដោយមានចំនួនយ៉ាងតិចរយៈ ពេលហុកសិក (៦០) ថ្ងៃ ចំពោះ វិធីសាស្ត្រ ដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ និងយ៉ាងតិចរយៈពេល សាមសិប (៣០) ថ្ងៃ ចំពោះវិធីសាស្ត្រដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក មុនកាលបរិច្ឆេទបើកសំណើដេញ ថ្លៃ នៅលើក្តាខៀនពត៌មាន ឬបញ្ជរព័ត៌មាន គេហទំព័ររបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ (បើមាន) គេហទំព័រលទ្ធកម្មសាធារណៈ សារព័ត៌មាន និង មធ្យោបាយផ្សព្វផ្សាយផ្សេងទៀត។ សេចក្តីជូន ដំណឹងនេះត្រូវមានពត៌មានសំខាន់ដូចខាងក្រោម៖

- ការពណ៌នាអំពីប្រភេទ និងបរិមាណនៃទំនិញ ការងារសាងសង់ ការងារជួសជុល ឬសេវាកម្ម
- តម្លៃប៉ាន់ស្មានសរុប
- ឈ្មោះអាស័យដ្ឋាន អ៊ីម៉ែល ទូរស័ព្ទ និងទូរសាររបស់អង្គភាពលទ្ធកម្ម
- វិធីសាស្ត្រលទ្ធកម្មដែលត្រូវអនុវត្ត
- ល័ក្ខខ័ណ្ឌនានានៃលក្ខណៈសម្បត្តិ ឬ បុរេលក្ខណៈសម្បត្តិ
- កាលបរិច្ឆេទ ពេលវេលា និងទីកន្លែង លក់ ទទួល និងបើកឯកសារដេញថ្លៃ ឬឯកសារកំណត់បុរេលក្ខណៈសម្បត្តិ
- តម្លៃលក់ឯកសារដេញថ្លៃ
- ការបញ្ជាក់អំពីល័ក្ខខ័ណ្ឌតម្រូវនៃប្រាក់កក់ធានាការដេញថ្លៃ និងប្រាក់ធានាការអនុវត្តកិច្ចសន្យា។

<u>**បំពេញសំណើដេញថ្លៃ៖**</u> នៅពេលទទួលបានឯកសារដេញថ្លៃ អ្នកដេញថ្លៃត្រូវធ្វើការសិក្សា គម្រោងឲ្យបានច្បាស់លាស់ ហើយបំពេញទម្រង់សំណើរដេញថ្លៃឲ្យបានត្រឹមត្រូវ ដូចខាងក្រោម៖

- ឈ្មោះអ្នកដេញថ្លៃ ឈ្មោះក្រុមហ៊ុន និងលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ អ្នកដេញថ្លៃ។
- តម្លៃឯកតា និងតម្លៃសរុបនៃលទ្ធផលនីមួយៗ។ តម្លៃសរុបនៃលទ្ធផលនីមួយៗ

ត្រូវតែស្មើ និងតំលៃឯកតា គុណនឹងចំនួនឯកតា។

- តម្លៃសរុបនៃការដេញថ្លៃ ។ តម្លៃសរុបនៃការដេញថ្លៃ ត្រូវតែស្មើនឹងផលបូក នៃ តម្លៃ ទាំងអស់ ។
- តម្លៃសរុបជាលេខ ត្រូវតែស្មើនឹងតម្លៃសរុបជាអក្សរ
- ចុះថ្ងៃខែឆ្នាំ ចុះហត្ថលេខា និងសរសេរឈ្មោះអ្នកដេញថ្លៃពីក្រោមហត្ថលេខា
- បន្ទាប់ពីបំពេញទម្រង់សំណើរដេញថ្លៃចប់សព្វគ្រប់ ត្រូវដាក់សំណើរដេញថ្លៃ នេះទៅក្នុងស្រោមសំបុត្រ ហើយបិទឲ្យជិត ដោយសរសេរ នៅលើខ្នងស្រោម សំបុត្រ ដូចខាងក្រោម៖

| |
|---|
| ឈ្មោះគម្រោង.................................... |
| ឈ្មោះអ្នកដេញថ្លៃ......................ឈ្មោះក្រុមហ៊ុន.................... |
| ចុះឈ្មោះនៅខេត្តក្រុង................លេខរៀងក្នុងបញ្ជី .................. |

សំណើដេញថ្លៃ គឺជាឯកសារសំងាត់នៃអ្នកដេញថ្លៃនីមួយៗ ។ ដូចនេះ មុនពេលគណៈ កម្មការ លទ្ធកម្មបើកស្រោមសំបុត្រដេញថ្លៃ តម្លៃដេញថ្លៃនៅក្នុងសំណើដេញថ្លៃមិន ត្រូវបានអនុញ្ញាតិ ឲ្យអ្នកណាដឹងឡើយ។ អ្នកដេញថ្លៃណាផ្តល់ពត៌មានអំពីដំលៃឯកតា និង/ឬ តម្លៃដេញថ្លៃ សរុបរបស់ខ្លួនទៅអ្នកដទៃ ឬ អ្នកពាក់ព័ន្ធក្នុងការអនុវត្តគម្រោងឃុំ សង្កាត់ណាម្នាក់ អ្នកទាំង នោះត្រូវចាត់ទុកថា "គឺជាការឃុបឃិតសុំគ្រលុំគ្នា" ។ អ្នក ដេញថ្លៃ ត្រូវបំពេញទម្រង់សំណើ ដេញថ្លៃ និងដាក់ក្នុងស្រោមសំបុត្រ ហើយបិទឲ្យជិត មុនពេលនៃការប្រជុំបើកសំណើដេញថ្លៃ។ ការបំពេញ សំណើរដេញថ្លៃនៅទីកន្លែងប្រជុំ បើកសំណើដេញថ្លៃ មិនត្រូវបានអនុញ្ញាតិជាដាច់ខាត។

អ្នកដេញថ្លៃត្រូវបំពេញទម្រង់សំណើដេញថ្លៃឲ្យបានត្រឹមត្រូវ។ បើមានចំណុច ណាមិនទាន់ យល់ច្បាស់ អ្នកដេញថ្លៃត្រូវសួរមន្ត្រីគាំទ្របច្ចេកទេសអំពីចំណុចដែលខ្លួន មិនទាន់ យល់ច្បាស់ នោះ។

ឈ្មោះក្រុមហ៊ុនដែលសរសេរលើខ្នងស្រោមសំបុត្រ ត្រូវតែដូចគ្នានឹងឈ្មោះ

ដែលមាន នៅក្នុងបញ្ជីឈ្មោះអ្នកទទួលការដែលមានសិទ្ធចូលដេញថ្លៃ។

អ្នកដេញថ្លៃត្រូវអាន និងចុះហត្ថលេខានៅលើសេចក្តីប្រកាសស្តីពីក្រមសីលធម៌ ការមិនក្លែងបន្លំ និងការមិនប្រព្រឹត្តអំពើពុករលួយ។ សេចក្តីប្រកាសនេះត្រូវច្រកក្នុងស្រោមសំបុត្រ ជាមួយនិងសំណើដេញថ្លៃ។ ក្នុងករណីអ្នកដេញថ្លៃមិនគោរពតាមសេចក្តីប្រកាសនេះ នឹងត្រូវបាន លុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកទទួលការជារៀងរហូត នឹងមិនត្រូវបានអនុញ្ញាតិឲ្យដាក់សំណើ ដេញថ្លៃគម្រោងឃុំ សង្កាត់ទាំងអស់ទូទាំងប្រទេសកម្ពុជា។

## ខ. ពេលដេញថ្លៃ (ការដាក់សំណើដេញថ្លៃ ការបើកសំណើ)

**<u>ការដាក់សំណើដេញថ្លៃ៖</u>** នៅពេលដល់វេលាដែលបានកំណត់សម្រាប់ការដាក់ និងទទួល សំណើដេញថ្លៃ គណៈកម្មការលទ្ធកម្មត្រូវចាប់ផ្តើមទទួលសំណើដេញថ្លៃរហូតដល់ ពេលផុត កំណត់ដាក់ និងទទួលសំណើដេញថ្លៃ។ ក្នុងកំឡុងពេលដាក់និងទទួលសំណើដេញថ្លៃនេះ មិនមែនជាពេលសម្រាប់អនុញ្ញាតិឲ្យអ្នកដេញថ្លៃបំពេញទម្រង់សំណើដេញថ្លៃនោះទេ។ អ្នកដេញថ្លៃត្រូវប្រគល់ស្រោមសំបុត្រសំណើដេញថ្លៃទៅឲ្យស្មានឃុំ សង្កាត់។ អ្នកដេញថ្លៃ ម្នាក់អាចដាក់សំណើដេញថ្លៃបានតែមួយប៉ុណ្ណោះសម្រាប់កិច្ចសន្យាមួយ។

គណៈកម្មការលទ្ធកម្មមិនត្រូវឈប់ទទួលសំណើដេញថ្លៃ មុនពេលវេលាដែលបានកំណត់ នៅក្នុងសេចក្តីជូនដំណឹងអំពីការដេញថ្លៃនោះទេ។ មុននឹងបញ្ចប់ការទទួលសំណើដេញថ្លៃ ប្រធានគណៈកម្មការលទ្ធកម្មត្រូវសួរបញ្ជាក់ទៅកាន់អ្នកដេញថ្លៃទាំងអស់ថា "តើមានអ្នកដេញ ថ្លៃណា មិនទាន់ដាក់សំណើដេញថ្លៃរបស់ខ្លួនដែរឬទេ?" ផុតរយៈពេលទទួលសំណើដេញថ្លៃ ស្មៀនឃុំ សង្កាត់ ត្រូវរាប់ស្រោមសំបុត្រសំណើដេញថ្លៃ ហើយរាយការណ៍ជូនប្រធានគណៈកម្មការ លទ្ធកម្មអំពីចំនួនស្រោមសំបុត្រសំណើដេញថ្លៃដែលបានទទួល។

អ្នកដេញថ្លៃមិនត្រូវបានអនុញ្ញាតិឲ្យធ្វើការផ្លាស់ប្តូរតម្លៃដាក់ដេញថ្លៃរបស់ខ្លួនឡើយ បន្ទាប់ពីផុតរយៈពេលនៃការដាក់សំណើដេញថ្លៃ។

**ការបើកសំណើដេញថ្លៃ៖** កិច្ចប្រជុំបើកសំណើដេញថ្លៃ គឺជាកិច្ចប្រជុំជាសាធារណៈ ។ គណៈកម្មការលទ្ធកម្មត្រូវចាប់ផ្តើម កិច្ចប្រជុំបើកសំណើដេញថ្លៃតាមពេលវេលា និងកាលបរិច្ឆេទកំណត់។ កិច្ចប្រជុំបើកសំណើដេញថ្លៃ អាចដំណើការទៅបាន លុះត្រាតែសមាជិក គណៈកម្មការ លទ្ធកម្មចូលរួមលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល។ ដំណើការកិច្ចប្រជុំបើកសំណើត្រូវអនុវត្តដូចខាងក្រោម៖

- ប្រធានគណៈកម្មាធិការលទ្ធកម្ម ត្រូវប្រកាសបើកការដេញថ្លៃជាផ្លូវការ និងប្រកាស គោលការសំខាន់នៃការដេញថ្លៃ
- អ្នកដេញថ្លៃឬ ដំណាងអ្នកដេញថ្លៃទាំងអស់ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធត្រូវបាន អញ្ជើញឲ្យចូលរួមកិច្ចប្រជុំបើកសំណើដេញថ្លៃ។ កិច្ចប្រជុំបើកសំណើដេញថ្លៃ នៅតែអាច ដំណើការទៅបានទោះបីជាពុំមានវត្តមានរបស់អ្នកដេញថ្លៃខ្លះ ឬ ទាំងអស់ក៏ដោយ។
- ប្រធានគណៈកម្មារធិការលទ្ធកម្ម ត្រូវបើកប្រអប់ដាក់សំណើ ដេញថ្លៃនោះនៅចំពោះមុខ សមាជិកគណៈកម្មកាធិការលទ្ធកម្មនិងអ្នកចូលរួមកិច្ចប្រជុំបើកសំណើដេញថ្លៃទាំងអស់
- ស្រោមសំបុត្រសំណើដេញថ្លៃត្រូវបានពិនិត្យត្រឹមត្រូវ ដើម្បីធានាថាស្រោមសំបុត្រទាំងនោះ ស្ថិតនៅក្នុងស្ថានភាពដើម។
- ស្រោមសំបុត្រសំណើដេញថ្លៃទាំងអស់ត្រូវរាប់និងដាក់នៅមុខគណៈកម្មាធិការលទ្ធកម្ម ដែលអាចឲ្យអ្នកចូលរួមទាំងអស់មើលឃើញច្បាស់។
- អ្នកដេញថ្លៃទាំងអស់មិនត្រូវបានអនុញ្ញាតឲ្យធ្វើការកែសម្រួលសំណើដេញថ្លៃ ឬ ដាក់ ឯកសារបន្ថែម ក្នុងកំឡុងពេលនៃការបើកសំណើដេញថ្លៃឡើយ ។
- នៅពេលបើកសំណើដេញថ្លៃ ត្រូវប្រកាស និងកត់ត្រានៅលើក្តាខៀននូវឈ្មោះ អ្នកដេញ ថ្លៃ ឈ្មោះក្រុមហ៊ុន តម្លៃដាក់ដេញថ្លៃ និងតួលេខចំនួនប្រាក់កក់ធានាការដេញថ្លៃ
- អ្នកដេញថ្លៃត្រូវបញ្ជាក់អំពីភាពត្រឹមត្រូវនៃពតិមាននានាដែលបានប្រកាស និងកត់ត្រា ពាក់ព័ន្ធទៅនឹងសំណើដេញថ្លៃរបស់ខ្លួន។ អ្នកដេញថ្លៃក៏អាចតវ៉ា

ផងដែរ ប្រសិនបើ សំណើដេញថ្លៃរបស់ខ្លួន មិនត្រូវបានបើក ឬ មានភាពមិនប្រក្រតី។

- សំណើដេញថ្លៃនីមួយៗដែលបានបើក ត្រូវចុះហត្ថលេខាសង្ខេបដោយសមាជិក គណៈកម្មាធិការលទ្ធកម្ម ដែលមានវត្តមានក្នុងកិច្ចប្រជុំបើកសំណើដេញថ្លៃ ។
- នៅមុនពេលបញ្ចប់ការបើកសំណើដេញថ្លៃ លេខាធិការនៃគណៈកម្មាធិការលទ្ធកម្ម ត្រូវបង្ហាញប្រអប់ដាក់ស្រោមសំបុត្រសំណើដេញថ្លៃទៅអង្គប្រជុំទាំងមូល។
- លេខាធិការនៃគណៈកម្មការលទ្ធកម្ម ត្រូវរៀបចំកំណត់ហេតុប្រជុំបើកសំណើដេញថ្លៃ ដែលត្រូវចុះហត្ថលេខាដោយសមាជិកគណៈកម្មាធិការលទ្ធកម្ម ដែលមានវត្តមាន ក្នុងកិច្ច ប្រជុំបើកសំណើដេញថ្លៃ។ កំណត់ហេតុកិច្ចប្រជុំនេះត្រូវថតចម្លងជូនគ្រប់អ្នកដេញថ្លៃ និងអ្នកចូលរួមសំណើដេញថ្លៃទាំងអស់។

☞ប្រសិនបើក្នុងដំណើការដេញថ្លៃលើកដំបូង ទទួលបានសំណើដេញថ្លៃតិចជាងបី គណៈកម្មាធិការលទ្ធកម្មមិនត្រូវបើកសំណើដេញថ្លៃទាំងនោះឡើយ និងត្រូវបញ្ជូនត្រឡប់ទៅឲ្យ អ្នកដេញថ្លៃវិញ ហើយត្រូវប្រកាសថា "ការដេញថ្លៃនេះបរាជ័យហើយ" និងត្រូវរៀបចំ ដំណើការដេញថ្លៃឡើងវិញ។ ហើយក្នុងដំណើការដេញថ្លៃឡើងវិញទោះបីទទួលបានសំណើ ដេញថ្លៃចំនួនប៉ុន្មានក៏ដោយ គណៈកម្មាធិការលទ្ធកម្មត្រូវតែបើកសំណើដេញថ្លៃទាំងអស់តាម កាលបរិច្ឆេទកំណត់។

## គ. ការអនុវត្តគម្រោង( ការដោះស្រាយការតវ៉ា ការតាមដានការអនុវត្ត និង ការវាយតំលៃ )

<u>ការដោះស្រាយការតវ៉ា៖</u> សម្រាប់អ្នកដេញថ្លៃដែលមិនយល់ព្រមទៅនឹងសេចក្ដីសម្រេចនានា ពាក់ព័ន្ធនឹងដំណាក់កាលនានានៅមុនពេលចុះកិច្ចសន្យា មានសិទ្ធិដាក់ពាក្យបណ្ដឹងទៅ ៖

- គណៈកម្មាធិការលទ្ធកម្ម ឬ
- ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ប្រសិនបើបណ្ដឹងតវ៉ារបស់ខ្លួន ពុំត្រូវបានដោះ

ស្រាយ ក្នុងកំឡុងពេលដប់ប្រាំ (១៥) ថ្ងៃ ឬខ្លួនមិនយល់ព្រមទៅនឹងដំណោះស្រាយ របស់ គណៈកម្មការ លទ្ធកម្ម ឬ

- ○ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ប្រសិនបើបណ្ដឹងតវ៉ារបស់ខ្លួនពុំត្រូវបាន ដោះស្រាយ ក្នុងកំឡុងពេលដប់ប្រាំ(១៥) ថ្ងៃ ឬខ្លួនមិនយល់ព្រមទៅនឹងដំណោះស្រាយ របស់ក្រុមប្រឹក្សាក្រុង ឬ គណៈកម្មការលទ្ធកម្ម ឬ
- ○ តុលាការ ប្រសិនបើបណ្ដឹងតវ៉ារបស់ខ្លួនពុំត្រូវបានដោះស្រាយក្នុងកំឡុងពេលដប់ប្រាំ(១៥) ថ្ងៃ ឬ ខ្លួនមិនយល់ព្រមទៅនឹងដំណោះស្រាយ របស់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។

☞គណៈកម្មាធិការលទ្ធកម្ម ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជាធានី ខេត្ត ត្រូវពិនិត្យ និងដោះស្រាយបណ្ដឹងតវ៉ា ឬឆ្លើយតបទៅអ្នកប្ដឹងក្នុងកំឡុងពេលដប់ប្រាំ (១៥)ថ្ងៃ បន្ទាប់ពីទទួលបានពាក្យបណ្ដឹងតវ៉ា។ ការដោះស្រាយវិវាទនិងបណ្ដឹងនៅក្នុដំណាក់កាលបន្ទាប់ ពីចុះកិច្ចសន្យា ត្រូវអនុវត្តទៅតាមល័ក្ខខ័ណ្ឌនៃកិច្ចសន្យា។

<u>**ការតាមដានការអនុវត្ត និងការវាយតំលៃ៖**</u> ការតាមដាន គឺជាដំណើការប្រមូលព័ត៌មានអំពីការរីកចម្រើនរបស់កិច្ចសន្យា។ ការប្រមូលពត៌មាននេះត្រូវធ្វើឡើងនៅគ្រប់នៃការអនុវត្ត កិច្ចសន្យា។ ការប្រមូលព័ត៌មាននេះ គឺជាផ្នែកមួយនៃការងារធម្មតា ពីមួយថ្ងៃទៅមួយថ្ងៃជាប្រចាំ។ គោលបំណងនៃការតាមដាន គឺដើម្បីជួយក្នុងការវិនិច្ឆ័យ ថាតើសកម្មភាពទាំងឡាយត្រូវបានអនុវត្ត ទៅតាម ផែនការគ្រោងទុកដែរឬទេ? ពត៌មានដែលប្រមូលបានត្រូវយកមកប្រើប្រាស់ ជាមូលដ្ឋាន ក្នុងការធ្វើសេចក្ដីសម្រេចអំពីការកែលំអរការគ្រប់គ្រង និងការអនុវត្តគម្រោង។

ការវាយតំលៃ គឺជាតំណើការវាស់វែងលទ្ធផលរបស់កិច្ចសន្យា ឬ លទ្ធផលដែលកិច្ចសន្យា ចង់បាន ដូចជាតើលទ្ធផលរបស់គម្រោងត្រូវបានសម្រេចប៉ុន្មានធៀបទៅនឹងអ្វីដែលយើងបាន សង្ឃឹមទុក? ជាងនេះទៅទៀត យើងអាចដកស្រង់បទពិសោធន៍អំពីការវាយតំលៃនេះ សម្រាប់យកទៅប្រើប្រាស់ក្នុងការអនុវត្តគម្រោងនាពេលអនាគតផងដែរ។ ដើម្បីធ្វើការវាយតំលៃ យើងត្រូវត្រួតពិនិត្យ និងវិភាគទៅលើ

ទិសដៅរបស់គម្រោង ដូចជាតើហេតុអ្វីបានជាយើងត្រូវ អនុវត្តគម្រោង ឬហេតុអ្វីបានជាយើងត្រូវសម្រេចឲ្យបាននូវទិសដៅរបស់គម្រោង ។ល។ ការវាយតំលៃគម្រោងមិនមែនជាសកម្មភាពដែលត្រូវធ្វើជាប្រចាំដូចជាការតាមដាននោះទេ ប៉ុន្តែវាជាសកម្មភាពដែលត្រូវអនុវត្តដាច់ដោយឡែក ដែលជាទូទៅនៅពេលបញ្ចប់គម្រោង។

ផ្នែកនេះផ្តោតសំខាន់តែទៅលើការតាមដានតែប៉ុណ្ណោះ ព្រោះថាការវាយតំលៃលើលទ្ធផល របស់គម្រោង គឺជាផ្នែកមួយនៃការវាយតំលៃលើការអនុវត្តជាទូទៅរបស់ឃុំ សង្កាត់ រហូតដល់ ពេលដែលក្រុមប្រឹក្សាត្រូវបញ្ចប់អាណត្តិការងាររបស់ខ្លួន។ នៅក្នុងឆ្នាំ ២០០៦ ក្រសួងមហាផ្ទៃ បានចេញគោលការណែនាំស្តីពីរបៀបធ្វើការវាយតំលៃនេះដល់ក្រុមប្រឹក្សា ឃុំ សង្កាត់។ តែទន្ទឹម នេះ ចាំបាច់ក៏ត្រូវធ្វើការវាយតំលៃ លើប្រសិទ្ធភាពនៃប្រព័ន្ធការងារមួយចំនួនដែលត្រូវបានដាក់ឲ្យ ប្រើប្រាស់កន្លងមក។ ក្នុងការវាយតំលៃនេះយើងត្រូវៈ

- វាយតំលៃជាទូទៅលើបទដ្ឋានបច្ចេកទេសដែលសម្រេចបាន
- វាយតំលៃលើសមត្ថភាព និងការអនុវត្តរបស់អ្នកទទួលការ
- វាយតំលៃលើសត្ថភាព និងការអនុវត្តរបស់អ្នកជំនួយបច្ចេកទេស និងអ្នកត្រួតពិនិត្យ បច្ចេកទេស។

បន្ថែមលើនេះទៅទៀត ផ្នែកទាំងអស់ខាងលើនេះមិនផ្តោតតែទៅលើការតាមដាន និង ការវាយតំលៃ គម្រោងមូលនិធិ ឃុំ សង្កាត់ នោះទេ វាអាចអនុវត្តបានដែរចំពោះគម្រោង ទាំងឡាយ ណាដែលត្រូវអនុវត្តដោយក្រុមប្រឹក្សាឃុំសង្កាត់។

## ២.ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ

### ក. ការផ្សាយព័ត៌មានអំពីលទ្ធកម្មសាធារណៈរបស់អាជ្ញាធរ

មេឃុំ ចៅសង្កាត់ត្រូវប្រកាសជូនដំណឹងអំពីការដេញថ្លៃ ដើម្បីអញ្ជើញរាល់អ្នកទទួលការ អ្នកផ្តល់សេវាកម្ម និងអ្នកផ្គត់ផ្គង់ទំនិញទាំងអស់ដែលមានសិទ្ធដាក់សំណើដេញថ្លៃ។ ការប្រកាស ជូនដំណឹងចំពោះកិច្ចសន្យាការងារ ឬ សេវាកម្មត្រូវបង្ហាញអំពីៈ

- លទ្ធផលនៃកិច្ចសន្យា

- ប្រភេទអ្នកទទួលការ ឬ អ្នកផ្តល់សេវាកម្មដែលត្រូវបានអនុញ្ញាតឲ្យចូលរួមដេញថ្លៃ
- ទីកន្លែងទំនាក់ទំនងរកឯកសារដេញថ្លៃ
- តម្លៃប៉ាន់ស្មាន
- ពេលវេលាផុតកំណត់ និងទីកន្លែងសម្រាប់ការដាក់ និងទទួលសំណើដេញថ្លៃ
- ពេលវេលា និងទីកន្លែងសម្រាប់ប្រជុំបើកសំណើដេញថ្លៃ ។

**ការប្រកាសជូនដំណឹងចំពោះការបញ្ជាទិញ ត្រូវបង្ហាញអំពី៖**

- ការពិពណ៌នាអំពីទំនិញដែលត្រូវទិញ
- ទីកន្លែងទំនាក់ទំនងរកឯកសារដេញថ្លៃ
- តម្លៃប៉ាន់ស្មាន ( នេះគឺជាការទិញដែលមានក្នុងថវិកាឃុំ សង្កាត់)
- ពេលវេលាផុតកំណត់ និងទីកន្លែងសម្រាប់កាដាក់ និងទទួលសំណើដេញថ្លៃ
- ពេលវេលា និងទីកន្លែងសម្រាប់ប្រជុំបើកសំណើដេញថ្លៃ ។

ការប្រកាសជូនដំណឹងអំពីការដេញថ្លៃ ត្រូវធ្វើជាសាធារណៈឲ្យទូលំទូលាយ ដោយបិទលើ ក្តារព័ត៌មានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងលើក្តាពត៌មានរបស់សាលារៀន ឬ ទីសាធារណៈ ដែលអាចធ្វើបាន។ ប្រសិនបើអ្នកទទួលការ អ្នកផ្តល់សេវាកម្ម និងអ្នកផ្គត់ផ្គង់ទំនិញមួយចំនួន មានលំនៅដ្ឋាននៅទីរួមស្រុក ខណ្ឌ នោះការប្រកាសជូនដំណឹងនេះ ត្រូវបិទលើក្តាពត៌មានស្រុក ខណ្ឌ ដូចគ្នាទៅនឹងខេត្ត ក្រុង និងឃុំ សង្កាត់ដែរ។ ការប្រកាសជូនដំណឹងនេះ ត្រូវបិទផ្សាយ ឲ្យបានរយៈពេល ២សប្តាហ៍ មុនពេលផុតកំណត់នៃការដាក់សំណើដេញថ្លៃ។

## ខ. ការទទួល ឬស្វែងរកព័ត៌អំពីលទ្ធកម្មសាធារណៈ

កិច្ចលទ្ធកម្មសាធារណៈមានន័យថា ជាការជ្រើសរើសអ្នកទទួលការ ឬអ្នកផ្តល់សេវាកម្ម ឬអ្នកផ្គត់ផ្គង់ និងការចុះកិច្ចសន្យាច្បាស់លាស់មួយអំពីការងារដែលពួកគេ

ត្រូវធ្វើ ពេលវេលា ដែលត្រូវអនុវត្ត តម្លៃ និងល័ក្ខខ័ណ្ឌចាំបាច់ផ្សេងៗទៀត។ លទ្ធផលនៃដំណើការលទ្ធកម្ម គឺជា ឯកសារនៃកិច្ចសន្យាមួយដែលមានចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់ និងអ្នកទទួលការ ឬអ្នក ផ្គត់ផ្គង់សេវាកម្ម។ រាល់ការចំណាយទាំងអស់ដែលប្រើប្រាស់ថវិកាឃុំ សង្កាត់ ផ្នែកអភិវឌ្ឍ ត្រូវតែ មានឯកសារយោងណាមួយភ្ជាប់មកជាមួយ (លើកលែងតែការចំណាយបេឡាបុរេប្រទាន)។ នៅក្នុងប្រទេសកម្ពុជា ដើម្បីទទួលបានពត៌មានអំពីការដេញថ្លៃជាសាធារណៈ គេត្រូវស្វែងរក តាមគេហទំព័រដូចខាងក្រោម ៖ http://www.ncdd.gov.kh/km/media-center/jobs-procurement ។ គេហទំព័រដែលបានបង្ហាញខាងលើ គឺជាគេហទំព័ររបស់រដ្ឋាភិបាលដែលមានការផ្សព្វផ្សាយ អំពី ដំណើការនៃការធ្វើលទ្ធកម្ម ឬ ការដេញថ្លៃជាសាធារណៈក្នុងប្រទេសកម្ពុជា ឬ ម្យ៉ាងវិញទៀត អ្នក ដែលមានបំណងចូលរួមក្នុងការដេញថ្លៃ ក៏អាចយកឯកសារពត៌មាន ឬ សំណុំបែបបទពី ទីចាត់ការ ផែនការ និងវិនិយោគខេត្ត ដែលខ្លួនមានបំណងចង់ដាក់ពាក្យដេញថ្លៃបានផងដែរ។

## ក.បទពិសោធន៍របស់សង្គមស៊ីវិល ក្នុងការអនុវត្តការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ

ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ របស់គម្រោង "**ពង្រឹងអភិបាលកិច្ចលទ្ធកម្ម ថ្នាក់ក្រោមជាតិ**" នៅក្នុងខេត្តកំពង់ធំរបស់អង្គការសីលការ ព័ត៌មានទាំងអស់ត្រូវបានផ្តល់ជូន អ្នកពាក់ព័ន្ធផ្សេងៗគ្នា ដូចជាមន្ត្រីក្រុង ក្រុមប្រឹក្សាសង្កាត់ និងមន្ត្រីអង្គភាពនានា បន្ទាប់ពីការ ផ្សព្វផ្សាយព័ត៌មានត្រូវបានរៀបចំ និងពិនិត្យរួចរាល់ ក្រោយពីធ្វើការកែលម្អតាមមតិស្ថាបនា រួចមក។ ការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ស្តីពីការរៀបចំបង្កើតគណៈកម្មការចម្រុះពង្រឹង អភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ ការកសាងសមត្ថភាពគណៈកម្មការចម្រុះពង្រឹងអភិបាលកិច្ច លទ្ធកម្មថ្នាក់ក្រោមជាតិ ស្តីពីច្បាប់ វិធាន បទបញ្ញត្តិទៅនឹងការងារលទ្ធកម្មសាធារណៈ ការចូលរួមសង្កេតការណ៍ប្រជុំដេញថ្លៃ ការពិនិត្យលើកិច្ចលទ្ធកម្មសាធារណៈ ការរៀបចំ ផ្សព្វផ្សាយ និងការប្រើប្រាស់ប្រអប់ដេញថ្លៃ ព្រមទាំងការប្រជុំពិគ្រោះយោបល់រវាងអាជ្ញាធរ ឯកជន និងគណៈកម្មការចម្រុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ ត្រូវបានបោះពុម្ព និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្រោយពីទទួលបានការឯកភាពពីអាជ្ញាធរ។ ឯកសារម្រាប់ផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ត្រូវបានចែកជូនយ៉ាងទូលំទូលាយជាខិតប័ណ្ណ កូនសៀវភៅ ។ល។ ក្នុងកំឡុងពេលយុទ្ធនាការសាធារណៈ ព្រមទាំងមានដាក់ជាក្តារព័ត៌មាន នៅតាមកន្លែងសំខាន់ៗមួយចំនួនទៀត ដើម្បីជាការងាយស្រួលសម្រាប់ប្រជាពលរដ្ឋស្វែងរក ព័ត៌មានស្តីពីការងាររបស់គម្រោង។

### ខ.ចំណុចត្រូវចងចាំនៅពេលអនុវត្តការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ

ក្នុងខណៈពេលធ្វើការងារទាក់ទងនឹង ការពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ នៅ សាលាក្រុង ជាពិសេស ក្រុងដែលមិនធ្លាប់មានប្រព័ន្ធវេទិកាពិគ្រោះយោបល់ និងការផ្តល់ព័ត៌មាន ត្រឡប់របស់ពលរដ្ឋ អង្គការសង្គមស៊ីវិលបានជួបប្រទះបញ្ហាប្រឈមជាច្រើន។ នៅក្នុងសៀវភៅ ណែនាំនេះ បានលើកយកការប្រឈមមួយចំនួន ដែលកើតចេញពីបទពិសោធន៍ និងការរៀនសូត្រ របស់អង្គការសីលការ និងដៃគូ

ព្រមទាំងមេរៀន សំខាន់ៗមួយចំនួន ដែលនឹងជួយដល់កិច្ចខិតខំ ប្រឹងប្រែងក្នុងការអនុវត្តគម្រោង។

- **ការបញ្ចុះបញ្ចូលមន្ត្រីក្រុង** ពីតម្រូវការ និងសារៈសំខាន់នៃការផ្សព្វផ្សាយពត៌មានជាសាធារណៈ និងការប្រឹងប្រែងច្រើនផ្សេងទៀត ដើម្បីឲ្យមានគណៈនេយ្យភាព និងការរីកចម្រើនក្នុងការអនុវត្ត ប្រទេសជាមួយរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ នៅក្នុងខេត្តកំពង់ធំ នៃប្រទេសកម្ពុជា ស្ថាប័ន អ្នកផ្តល់សេវា (ទាំងសាលាក្រុង និងអ្នកផ្តល់សេវាឯកជន) ត្រូវបានពន្យល់ណែនាំតាមរយៈកិច្ចប្រជុំ និងកិច្ចពិភាក្សាស្តីពីភាពសំខាន់នៃការផ្សព្វផ្សាយពត៌មានជាសាធារណៈ សារៈសំខាន់នៃការ ចូលរួមប្រជុំដេញថ្លៃរបស់ពលរដ្ឋ ការពិនិត្យលើកិច្ចលទ្ធកម្មសាធារណៈ ការរៀបចំផ្សព្វផ្សាយ និង ការបើកសំណើដេញថ្លៃ។
- **ការបង្កើនការយល់ដឹង** ពិតជាសំខាន់ណាស់ ដោយសារជាទូទៅពលរដ្ឋ ក៏ដូចជាមន្ត្រី សាលា ក្រុង មានការយល់ដឹងតិចតួចទាក់ទងនិងទស្សនទាននៃការផ្សព្វផ្សាយពត៌មានជាសាធារណៈ អំពីលទ្ធកម្ម និងអត្ថប្រយោជន៍របស់ ការងារលទ្ធកម្មក្នុងប្រទេសកម្ពុជាដែលត្រូវបានដំណើរការ តាំងពីឆ្នាំ ១៩៩៥ ដោយរដ្ឋាភិបាលនៃប្រទេសកម្ពុជា។
- **ការប្រមូលព័ត៌មាន/ទិន្នន័យ** សម្រាប់ចងក្រងការផ្សព្វផ្សាយពត៌មានជាសាធារណៈអំពីលទ្ធកម្ម ក៏ជាបញ្ហាប្រឈមមួយដែរ ពីព្រោះ ដើម្បីជាការទទួលបានព័ត៌មាននេះ អ្នកចងក្រង ត្រូវសាកសួរ អ្នកកាន់គម្រោង ត្រូវប្រមូលព័ត៌មានពីបណ្តាស្ថាប័នក្រុង អង្គភាពផ្តល់សេវារបស់រដ្ឋ និងភ្នាក់ងារ ដទៃទៀត។
- **បញ្ហាដទៃទៀត** ដែលអាចពន្យាដំណើរការនៃការបង្កើតការផ្សព្វផ្សាយពត៌មានជាធារណៈបាន មានដូចជា ការខ្វះការសហការណ៍ពីអាជ្ញធរក្នុងតំបន់ រក្សាទិន្នន័យហួសសម័យ កង្វះខាត បុគ្គលិកជំនាញឬ អ្នកបច្ចេកទេស និងភស្តុភារនៅក្នុងសាលាក្រុង។
- **អង្គភាពមូលដ្ឋានក្រុង** អាចមានការស្ទាក់ស្ទើរក្នុងការផ្សព្វផ្សាយព័ត៌មានដូចជារយៈពេលនៃការដោះស្រាយការតវ៉ាសេវាផ្សេងៗគ្នា និងការទទួលខុសត្រូវដោះស្រាយការតវ៉ា តាមកាលកំណត់ ព្រមទាំងជូនខ្លះបង្ហាញពីកង្វះសមត្ថភាពក្នុងការដោះស្រាយការ

តវ៉ា។

**គ.មេរៀនជាបទពិសោធន៍**

- វិធីសាស្ត្រដ៏មានប្រសិទ្ធភាពសម្រាប់ទទួលបានការសហការពីមន្ត្រី នៅកម្រិតមូលដ្ឋាន គឺតំបូង ឡើយត្រូវស្វែងរកការគាំទ្រពីមន្ត្រីជាន់ខ្ពស់ និងក្រសួងនៅថ្នាក់រដ្ឋ ខេត្ត/ជាតិ។ ជាញឹកញយ ទោះបី ជាមានការប្រឹងប្រែងធ្វើវិមជ្ឈការ និងការផ្ទេរសិទ្ធិអំណាច ក៏មានអាជ្ញាធរមូលដ្ឋានខ្លះមិនហ៊ាន ចាត់វិធានការណ៍ភ្លាមៗដោយគ្មាន ការឯកភាពពីថ្នាក់លើ ឬមន្ត្រីជាន់ខ្ពស់នោះទេ។ ដូច្នេះ គួរទាក់ទងថ្នាក់លើ ដែលមានការពាក់ព័ន្ធមុននឹងទាក់ទងជាមួយមន្ត្រីមូលដ្ឋាន។ នៅកម្រិតក្រុង គប្បីទាក់ទង អភិបាលក្រុង នឹងជម្រាបពួកគាត់ពីសកម្មភាពនានា ហើយសុំការគាំទ្រពីបណ្តា មន្ត្រីពាក់ព័ន្ធ។ ជាឧទាហរណ៍ នៅខេត្តកំពង់ធំនៃប្រទេសកម្ពុជា ដែលជាគោលដៅនៃការអនុវត្ត គម្រោង "ពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ" របស់អង្គការសីលការ ដែលមាន អង្គការម៉ូដ ជាដៃគូ ហើយនិងមានគណ:កម្មការចម្រុះពង្រឹងអភិបាលលកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (គ.ព. អ.ល.) ជាអ្នកសង្កេតការណ៍ផ្ទាល់នៅតាមមូលដ្ឋានដែលពួកគេរស់នៅ នាយកប្រតិបត្តិរបស់ អង្គការសីលការ និងប្រធានគម្រោងដែលទទួលបន្ទុកផ្នែកពង្រឹងអភិបាលកិច្ចលទ្ធកម្ម ថ្នាក់ក្រោមជាតិ បានជម្រាបជូនអភិបាលនៃគណ:អភិបាលខេត្តកំពង់ធំ អំពីគម្រោងដែលអង្គការសីលការ បានទទួលការអនុញ្ញាតិពីក្រសួងមហាផ្ទៃ អភិបាលនៃគណ:អភិបាលខេត្តកំពង់ធំ ក៏បានបង្ហាញ នូវការគាំទ្រយ៉ាងមុតមាំ ចំពោះការអនុវត្តគម្រោងរបស់អង្គការសីលការ និងការអង្គការម៉ូដ និងបានជួយសម្រួលនូវការអនុវត្តគម្រោងឲ្យមានភាពងាយស្រួលបន្ថែមទៀតផង។
- **ការផ្សព្វផ្សាយព័ត៌មានជាសាធារណ:** មិនអាចផ្លាស់ប្តូរផ្នត់គំនិតរបស់មន្ត្រីសាលាក្រុង មន្ទីរខេត្ត អាជ្ញាធរពាក់ព័ន្ធ និងពលរដ្ឋបានភ្លាមៗនោះទេ ការផ្លាស់ប្តូរនេះត្រូវការពេលវេលា។ ដូច្នេះដើម្បី សំរេចបាននូវការផ្លាស់ប្តូរទាំងនេះពិតជាត្រូវការការខិតខំប្រឹងប្រែងយ៉ាងសកម្ម និងស្វាហាប់។
- **ការបង្កើនការយល់ដឹងរបស់ពលរដ្ឋ** និងការជម្រុញពលរដ្ឋឲ្យយល់ដឹងពីគុណសម្បត្តិនៃការផ្សព្វផ្សាយជាសាធារណ:អំពីការដេញថ្លៃ ដែលសាលាក្រុងបានបង្កើតឡើងពិតជាមានសារ:សំខាន់ក្នុងការជួយឲ្យប្រព័ន្ធទាំងនោះមានដំណើរការនិងមានប្រយោជន៍។

នៅពេលដែល ពលរដ្ឋដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួនចំពោះការតាមដានការងារលទ្ធកម្ម ឬការដេញថ្លៃ នៅក្នុងឃុំ សង្កាត់របស់ពួកគេ ពលរដ្ឋចាប់ផ្តើម បង្កើនការទាមទារឲ្យបង្កើនគុណភាពសេវា ដែល ជម្រុញឲ្យស្ថាប័នផ្តល់សេវា ឬមន្ត្រីរក្សាកម្រិតសេវា និងបង្កើនគុណភាព ឬប្រសិទ្ធភាព ចំពោះ ការងាររបស់ពួកគេ។

## ឃ.ឧទាហរណ៍ខ្លះនៃការអនុវត្តគម្រោងក្នុងខេត្តកំពង់ធំចំពោះការផ្សព្វផ្សាយព័ត៌មាន

អង្គការសីលការ ក្រោមការឧបត្ថមពីមជ្ឈមណ្ឌលអន្តរជាតិសម្រាប់សហគ្រាសឯកជន (CIPE) បានកំពុងអនុវត្តគម្រោងពង្រឹងអភិបាលកិច្ចថ្នាក់ក្រោមជាតិ (ព.អ.ល.ថ) ។ ព.អ.ល.ថ គឺជាគំនិតផ្តួចផ្តើមរយៈពេលវែង សម្រាប់ធ្វើឲ្យអភិបាលកិច្ចសាធារណៈនៅប្រទេសកម្ពុជា មានភាពប្រសើរឡើង តាមរយៈការបង្កើនតម្លាភាព និងគណនេយ្យភាពក្នុងអភិបាលកិច្ចសាធារណៈ ថ្នាក់មូលដ្ឋាន។ អង្គការសីលការ រួមចំណែកកសាងសមត្ថភាពស្ថាប័នពាក់ព័ន្ធ ដូចជាស្ថាប័ន ឯកជន និងសាធារណៈ ក្នុងការត្រួតពិនិត្យដំណើការកិច្ចលទ្ធកម្មសាធារណៈ នៅថ្នាក់ក្រោមជាតិ ចំពោះភាពមិនប្រក្រតី និងចូលរួមក្នុងការជួយគាំទ្រដើម្បីធ្វើឲ្យប្រសើរឡើង។ ទន្ទឹមគ្នាជាមួយនឹងការអនុវត្តគម្រោងក្នុងខេត្តកំពង់ធំនោះ ប្រធានគម្រោងដែលជាបុគ្គលិករបស់អង្គការសីលការ បានប្រើវិធីសាស្ត្រមួយចំនួនក្នុងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ អំពីការងារ និងគម្រោងរបស់ខ្លួន ក្នុងខេត្តកំពង់ធំ ហើយរបៀបនៃការផ្សព្វផ្សាយព័ត៌មាននោះមាន ១០ប្រការដូចខាងក្រោម៖

- ប្រការទី១៖ អង្គការសីលការ សហការណ៍ជាមួយអង្គការ ម៉ូដ ដែលមានទីតាំងនៅក្នុងទីរួម ខេត្តកំពង់ធំ ក្នុងការអញ្ជើញ សមាជិករបស់ គណៈកម្មការចម្រុះពង្រឹងអភិបាលកិច្ចលទ្ធកម្មថ្នាក់ ក្រោមជាតិ មកប្រជុំគ្នាដើម្បីធ្វើការសិក្សា ក៏ដូចជាទទួលពត៌មានថ្មី ហើយនឹងរបៀប នៃការ ធ្វើការ ក្នុងនាមជាអ្នកស្ម័គ្រចិត្ត និងជាគណៈកម្មការចម្រុះពង្រឹងងអភិបាលកិច្ចលទ្ធកម្ម ថ្នាក់ក្រោមជាតិ។
- ប្រការទី ២៖ ការអនុវត្តគម្រោងរបស់អង្គការ សីលការ ពាក់ព័ន្ធជាមួយនឹងការផ្សព្វផ្សាយ ព័ត៌មាននោះ គឺការផ្ញើសារ ឬ អ៊ីម៉ែល ទៅកាន់អង្គការ ម៉ូដ ហើយបន្ទាប់មក

អង្គការ ម៉ូដ ផ្សព្វផ្សាយពត៌មានបន្តទៅកាន់សមាជិកគណៈកម្មាការចម្រុះពង្រឹងកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (គ.ព.អ.ល.)។

- ប្រការទី ៣៖ ក្នុងការផ្សព្វផ្សាយពត៌មានដែលពាក់ព័ន្ធជាមួយនឹងការងាររបស់គម្រោង អង្គការសីលការ ក៏មានការផ្សព្វផ្សាយតាមវិទ្យុ១០៣.៥MHz ក្នុងខេត្តកំពង់ធំផងដែរ។ ឧទាហរណ៍ នៅពេលដែលមានការផ្សព្វផ្សាយអំពីការងារលទ្ធកម្ម ឬការបកស្រាយអំពីអភិបាលកិច្ចល្អ ដែល មាន ការអញ្ជើញចូលរួមពីវាគ្មិនកិត្តិយស ដែលអញ្ជើញមកពីមន្ទីខេត្ត ឬអ្នកជំនាញទៅតាម ប្រធានបទណា មួយនោះ ការផ្សព្វផ្សាយពត៌មានតែងតែត្រូវបានធ្វើឡើងតាមរយៈវិទ្យុ១០៣.៥MHz ក្នុងខេត្តកំពង់ធំ។
- ប្រការទី៤៖ អង្គការសីលការ ក៏មានការផ្សព្វផ្សាយ អំពីការងារលទ្ធកម្ម ឬការដេញថ្លៃ តាមរយៈការសៃត កោះសន្តិភាព និងកម្ពុជាថ្មី ផងដែរ។
- ប្រការទី៥៖ អង្គការសីលការ មានការផ្សព្វផ្សាយព័ត៌មានទាក់ទងជាមួយនឹងការងារគម្រោង នៅខេត្តកំពង់ធំនៅតាមបណ្តាញទំនាក់ទំនងសង្គមផងដែរ ជាឧទាហរណ៍ អង្គការសីលការ បានបង្រៀនសមាជិកគណៈកម្មាការចម្រុះពង្រឹងកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (គ.ព.អ.ល.) ឲ្យចេះប្រើ បណ្តាញទំនាក់ទំនងសង្គម ហើយពួកគាត់ក៏មានទំព័រ ហ្វេសប៊ុក ដែលប្រើឈ្មោះជាភាសាអង់គ្លេសថា JPMC KAMPONG THOM សម្រាប់ធ្វើការបង្ហោះព័ត៌មានជាសកម្មភាពដែលពួកគាត់ បានបំពេញក្នុងនាមជាសមាជិកគណៈកម្មាការចម្រុះពង្រឹងកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ(គ.ព.អ.ល. )
- ប្រការទី ៦៖ អង្គការសីលការ បានចាប់ដៃជាមួយអង្គការ ម៉ូដ ក្នុងអនុវត្តគម្រោងនៅ ខេត្តកំពង់ធំ ព្រោះហេតុនោះមានករណីជាច្រើនដែលអង្គការសីលការ និងអង្គការម៉ូដបាន ពឹងពាក់គ្នា ទៅវិញទៅមក ជាឧទារហណ៍អង្គការសីលការអាចស្នើឲ្យអង្គការម៉ូដបិទក្រដាស ផ្សព្វផ្សាយព័ត៌មាននៅអង្គការ ម៉ូដ និងនៅកន្លែងទីស្នាក់ការរបស់ សមាជិកគណៈកម្មាការចម្រុះ ពង្រឹងកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (គ.ព.អ.ល.) ដែលមានទីតាំងក្នុងភូមិ ត្រពាំងឫស្សី។ ត្រង់ចំណុច នេះ យើងអាចនិយាយបានថា ការផ្សព្វផ្សាយពត៌មានរបស់អង្គការ សីលការ ក៏មានការបិទតាម នៅតាមក្តារព័ត៌មានសាធារណៈរបស់អង្គការម៉ូដ និងក្តារព័ត៌មានរបស់សមាជិកគណៈកម្មាការ ចម្រុះពង្រឹងកិច្ចលទ្ធកម្មថ្នាក់ក្រោមជាតិ (គ.ព.អ.ល.)។

- ប្រការទី ៧៖ នៅក្នុងការផ្សព្វផ្សាយពត៌មានជាសាធារណៈ ចំពោះការអនុវត្តគម្រោង របស់ខ្លួនក្នុងខេត្តកំពង់ធំនោះ អង្គការសីលការ ក៏បានរៀបចំជាខិត្តប័ណ្ណពត៌មាន សៀវភៅតូចៗ ហើយនិងប័ណ្ណប្រកាសពត៌មាន ស្ដីពីការងាររបស់គម្រោងដែលបានអនុវត្តនៅក្នុងខេត្តកំពង់ធំ ផងដែរ។
- ប្រការទី ៩៖ អង្គការសីលការ បានអនុញ្ញាតឲ្យមានការផ្សព្វផ្សាយរបាយការណ៍ ស្ដីពី សកម្មភាពនៃការអនុវត្តគម្រោងជាសាធារណៈ ព្រោះហេតុនោះ អង្គការសង្គមស៊ីវិល ឬ អ្នកដែលចង់ដឹងពីសកម្មរបស់អង្គការសីលការ ឬ អ្នកដែលចង់សិក្សាពីការអនុវត្តគម្រោង ក៏ដូចជា ការងាររបស់អង្គការសីលការ អាចទាញយករបាយការណ៍ ឬ ឯកសាររបស់អង្គការសីលការ ពីប្រព័ន្ធអ៊ីនធើណែតបាន។
- ប្រការទី១០៖ ក្នុងការអនុវត្តនូវការងាររបស់ខ្លួនកន្លងមក អង្គការសីលការបានធ្វើជា យុទ្ធនាការផ្សព្វផ្សាយ ហើយយុទ្ធនាការនោះក៏ត្រូវបានចាក់ផ្សាយតាមរយៈទូរទស្សន៍ក្នុង ប្រទេស កម្ពុជា ទៀងផង។ ជាក់ស្ដែង កាលពីឆ្នាំកន្លងទៅ អង្គការសីលការបានធ្វើយុទ្ធនាការមួយ ស្ដីពី សារៈសំខាន់នៃការធ្វើលទ្ធកម្ម នៅក្នុងខេត្តកំពង់ធំដែលនៅក្នុងពេលនោះមានការដើរជាក្បួន មានពាក្យស្លោកអំពីលទ្ធកម្ម និងមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋជាច្រើន ហើយកម្មវិធីនោះ ត្រូវបានចាក់ផ្សាយតាមទូរទស្សន៍បន្ថែមទៀត ដើម្បីជាការចែករំលែកព័ត៌មានដល់សាធារណៈជន ទូទៅឲ្យបានជ្រាប និងបានយល់ពីការធ្វើលទ្ធកម្ម និងគុណសម្បត្តិនៃការធ្វើលទ្ធកម្ម។

## ឯកសារយោង

- សៀវភៅណែនាំស្តីពី ការអនុវត្តគម្រោងមូលនិធិ ឃុំ សង្កាត់ ឆ្នាំ ២០០៩
- សេចក្តីណែនាំស្តីពីវិធីសាស្រ្ត និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌលេខ ០០២
- ធម្មនុញ្ញពលរដ្ឋ និងការផ្សព្វផ្សាយពត៌មាន
- Public procurement: Transparency revised? Phnom Penh Post, Fri, 5 April 1996.
- ទស្សនៈព្រឹត្តិការណ៍ខ្មែរ វិទ្យុបារាំង ថ្ងៃ ពុធ 20 វិច្ឆិកា 2013។



**សហការអនុវត្តដោយ**

**គាំទ្រថវិកា**


អង្គការសីលការ ផ្ទះលេខ៥៥B-៥៥C ផ្លូវលេខ៣៩០
សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ:០២៣ ២១៧ ៨៧២/២១០ ៩០២/០១២ ៧៩ ២៣ ៧៩
អ៊ីមេល: silaka@silaka.org វិបសាយ: www.silaka.org

អង្គការម៉ូដ ផ្ទះលេខ១៣ ផ្លូវលេខ១ ភូមិកំពង់ធំ
សង្កាត់កំពង់រទេះ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ
អ៊ីមេល: sinalpeanh@modecambodia.org
វិបសាយ: www.modecambodia.org